ក 204

ទស្សនាវដ្តី លេខ ៩

# ពុទ្ធិកវិទ្យាល័យ



ទីចាត់ការ វត្តលង្កា សង្កាត់លេខ ៦

ភ្នំពេញ

ក 204

1956 - 9

ក- ២០4

# មាតិការឿង


| | | |
|---|---|---|
| បណ្ណាធិការ | វិចារណកថា | ទំព័រទី ១ |
| | ដំណើរសាសនា | ,, ៤ |
| មហា ថោង-ទិត | ស្មានការណ៍នៅសហភាពភូមា | ,, ៨ |
| | បុណ្យរំលឹកព្រះពុទ្ធសាសនា | ,, ១៤ |
| | ពុទ្ធប្រវត្តិ | ,, ១៧ |
| | សេចក្ដីរាយការណ៍អំពីការប្រជុំនៃ<br>គណៈកម្មាធិការទីប្រឹក្សាពុទ្ធគយា | ,, ២០ |
| ភិក្ខុ លី-គឹមឡុង | ពិធីបុណ្យធ្លងឆ្លងសង្គាយនា | ,, ២៤ |
| ព្រះពុទ្ធវង្ស កៅ-ស៊ឹម | បុរាណនិវេសន៍ | ,, ២៧ |
| ព្រះគ្រូបុរត្ថិមពាលី អ៊ុ-បេវ | ធនញ្ជយបណ្ឌិត | ,, ៣០ |
| លោក តៃ-ដុន | ជ័យប្រាជ្ញ (ត) | ,, ៣៣ |
| | ពាក្យជីរបស់គណកម្មការវប្បធម៌ | ,, ៣៨ |


## ថ្លៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# សេចក្ដីជូនដំណឹង

សូមព្រះថេរានុត្ថេរៈនឹងអស់លោក-អ្នក-មិត្តទាំងឡាយ ដែលបានជាវទស្សនាវដ្ដីនេះ ហើយពុំទាន់បានបង់តម្លៃជាវនៅឡើយនោះ សូមទានមេត្តាផ្ញើបច្ច័យ ប្រាក់ទៅបង់តម្លៃឲ្យទានដោយអនុគ្គហភាព ។ ព្រោះពលភាពនៃថវិកាសម្រាប់បំណាយបោះពុម្ពនោះ កាន់តែខ្សត់ខ្សោយណាស់ទៅហើយ ។

សូមព្រះថេរានុត្ថេរៈនឹងអស់លោក-អ្នក-មិត្តទាំងឡាយ មេត្តាជួយឧបត្ថម្ភទំនុកបំរុងជីវភាពនៃទស្សនាវដ្ដីនេះឲ្យមានពលភាព-វឌ្ឍនភាពជាស្ថាពរតទៅឲ្យទានផង ! ។

សូមអរគុណទុកជាមុនដ៏ជ្រាលជ្រៅដោយសេចក្ដីស្មោះស្ម័គ្រ ! ។

# វិចារណកថា

## សមណនិស្សិត នឹង កូដកម្ម

ពុទ្ធសករាជ២៤៩៩ កំពុងតែរំកិលចូលទៅជិតដល់កាល ២៥០០ ដែលពុទ្ធជនពិភពលោកទាំងមូលកំពុងតែពួតដៃគ្នា ដើម្បីធ្វើបុណ្យរំលឹកឆ្នាំ២៥០០ គេក៏បានកត់ត្រាទុកថា ជាពាក់កណ្ដាលនៃពុទ្ធសាសនកាល ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដំកល់សាសនានេះទុកត្រឹមតែ៥.០០០វស្សាជាអាយុកល្បនៃសាសនារបស់ព្រះអង្គ ។

យើងធ្លាប់ដឹងមកហើយថា ព្រះពុទ្ធសាសនាដែលនឹងរុងរឿងបានទៅអនាគតក៏ដោយអាស្រ័យពុទ្ធបរិស័ទទាំងបួនពួក ដែលទុកជាជើងក្ការបួនសម្រាប់ដំកល់ជើងពានទ្រព្រះត្រ័យរតន ជាឱវាទព្រះបរមគ្រូជាម្ចាស់ ។ ដើម្បីនឹងបញ្ជាក់រឿងនេះឲ្យច្បាស់ទៅលើការលើកដំកើងព្រះពុទ្ធសាសនា ក៏គួរយើងគិតដល់វិធីលើកស្ទួយព្រះពុទ្ធសាសនាជាមុនសិន ចុះធ្វើដូចម្ដេចទៅ ដើម្បីនឹងឲ្យឃើញដល់លើកការស្ទួយព្រះពុទ្ធសាសនា? ក្នុងរឿងនេះ យើងមិនបាច់យកគោលសំខាន់ឯណាផ្សេងមកពោលឲ្យវែងឥតប្រយោជន៍នោះទេ សូមមិត្តពុទ្ធជនគ្រប់ឋានៈ លើកយកបញ្ហាសាមគ្គីធម៌មកពិចារណាជាមួយនឹងខ្ញុំម្ដង ៗ នោះប្រហែលជាយើងនឹងឃើញពន្លឺព្រឹល ៗ នៃការរុងរឿងខ្លះមិនខាន ។

ពុទ្ធបរិស័ទទាំង៤ពួកនេះ មានភិក្ខុសង្ឃដែលជាជន្ទល់ទី ១ ក្នុងផ្ទៃនៃព្រះពុទ្ធសាសនាទាំងមូល ហើយភិក្ខុសង្ឃនេះមានករណីយកិច្ចដាច់ដោយឡែក លើការផ្សាយព្រះពុទ្ធសាសនា ។ ដូច្នោះព្រះសង្ឃ ត្រូវរស់នៅតាមឱវាទរបស់ព្រះពុទ្ធដែល

មានសាមគ្គីធម៌ជាបាទ ហើយនឹងបរិស័ទ៣ជំពូកក្រៅទៀតក៏ត្រូវតែបង្ហាប់រួមកំឡាំងគ្នា ដើម្បីកសាងអនាគតនៃការផ្សាយព្រះពុទ្ធសាសនាដែរ ចុះបើបរិស័ទទាំង៤ជំពូកនេះមានសាមគ្គីធម៌ប្រេះឆាទៅហើយ ពេលណាហ្ន៎ ព្រះពុទ្ធសាសនាប្រទេសយើងនឹងមានកម្លាំងទៅអនាគតបាន ?

យើងដឹងច្បាស់ណាស់ថា ក្នុងពេលថ្មីៗ ដែលទើបតែកន្លងផុតទៅ គេឃើញសមណនិស្សិត ដែលកំពុងតែសិក្សាក្នុងវិទ្យាល័យព្រះសុរាម្រិត្យ ក៏បែរទៅជាមានរឿងហេតុអ្វីមួយ នាំឲ្យសមណនិស្សិតទាំងនោះ បង្អង់ការសិក្សាព្រមគ្នាតែម្តង ដែលពាក្យលោកជន ឲ្យឈ្មោះថា «សមណនិស្សិតធ្វើកូដកម្ម» គួរឲ្យយើងឆ្ងល់ដែរក្នុងរឿងនេះ ជាច្រើនឆ្នាំមកហើយ អំពើបែបនោះ យើងមិនដែលជួបប្រទះសោះ ក្នុងផ្ទៃនៃព្រះពុទ្ធសាសនាប្រទេសកម្ពុជា ចុះពេលនេះ រឿងរ៉ាវ ដូចម្តេចហ្ន៎ បានជាហេតុនោះកើតមានឡើងក្នុងវេលាជាពាក់កណ្តាលនៃព្រះពុទ្ធសាសនាយ៉ាងនេះ គួរឲ្យស្តាយណាស់ បើសិនណាជាយើងបានដឹងរឿងនោះមុន ប្រហែលជារបៀបនោះនឹងមិនមានផ្ទុះឡើងបានឡើយ ? តែទោះបីដូចម្តេចក៏ដោយ ក៏ការនោះជ្រុលហួសទៅហើយដែរ ហើយកើតឡើងក្នុងផ្ទៃនៃព្រះពុទ្ធសាសនាទៀត គួរតែយើងផ្គុំសាមគ្គី ដើម្បីការរស់នៅនៃសមណនិស្សិតទាំងនោះផង ? កំហុសទាំងឡាយដែលមានកើតឡើង ក៏មិនមែនជាកំហុសធំដុំដែរ បើសិនជាយើងបានពិចារណាឲ្យសមតាមហេតុផលទៅ តែបើយើងចោទចំ ថាសមណនិស្សិតធ្វើកូដកម្ម ប្រឆាំងនឹងបំណងរបស់រាជរដ្ឋាភិបាលវិញនោះ ក៏ឃើញថាហួសហេតុបន្តិចទៅដែរ ព្រោះតាមពិតសមណនិស្សិតទាំងនោះ

តទៅទំព័រទី១២

# ដំណឹងសាសនា

## បុណ្យកតញ្ញូកតវេទី

## បំពោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណមហានិកាយ (ត)

សម្តេចប្រកបដោយព្រះគុណទាំងពីរប្រការដូចបានថ្លែងមកហើយនេះ ទើបជាទីស្រឡាញ់ជាទីគោរព នៃយើងខ្ញុំគ្រប់គ្នា ៗ បានជាយើងខ្ញុំគ្រប់គ្នា មានសេចក្តីស្លុតរន្ធត់ក្នុងចិត្តយ៉ាងក្រៃលែងក្នុងវេលាដែលសម្តេចមានព្រះជរាពាធ ទើបនាំគ្នាធ្វើបុណ្យកតញ្ញូកតវេទីកិច្ចនេះ បាននិមន្តព្រះសង្ឃចំរើនព្រះបរិត្ត និមន្តធម្មកថិកសំដែងធម្មទេសនា ប្រគេនភេសជ្ជៈ ប្រគេនភត្តាហារចំពោះព្រះសង្ឃដើម្បីយកភាគផល ប្រគេនផ្ទាល់ចំពោះសម្តេច ៗ

មួយទៀត យើងខ្ញុំសូមអំពាវនាវដល់កុសលទាំងឡាយជាដើម, សូមកុសលទាំងនោះ ផុសផុលឡើងមករួមកម្លាំងជាមួយគ្នានឹងការកុសលដែលយើងខ្ញុំធ្វើប្រគេនសម្តេចក្នុងគ្រាឥឡូវនេះ, សូមអតីតកុសលរបស់សម្តេច នឹងបច្ចុប្បន្នកុសលរបស់យើងខ្ញុំ ផ្តុំកម្លាំងគ្នា គាំពារសម្តេច កុំឲ្យមានទុក្ខវេទនា, សូមកុសលទាំងនោះក្លាយមកជាឱសថទិព្វ ស្រោចស្រប់រម្ងាប់រោគក្នុងព្រះកាយសម្តេច ឲ្យបានសម្រេចជាសះស្បើយយ៉ាងឆាប់ ៗ សូមសម្តេចប្រកបដោយព្រះជន្មាយុយឺនយូរវែងឆ្ងាយ ដើម្បីជាទីគោរពនៃយើងខ្ញុំទាំងឡាយអស់កាលជាអង្វែងតរៀងទៅ

លុះចប់សុន្ទរកថានេះហើយ, ព្រះតេជព្រះគុណព្រះពុទ្ធវង្សកៅ - ស៊ុម សាស្ត្រា

ចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត្យ ជាតំណាងសម្ដេចបានថ្លែងសង្វេគប្បកាសចំពោះ សិស្សានុសិស្សទាំងអស់ មានសេចក្ដីគួរឲ្យរន្ធត់ចិត្តជាពន់ពេក ដែលយើងបកមកចុះជូន ទាំងស្រុងដូចខាងក្រោមនេះ ៗ

សូមនមស្ការ សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកវត្តឧណ្ណាលោម

ព្រះតេជព្រះគុណព្រះពោធិវង្សវាងហ្វានពុទ្ធិកវិទ្យាល័យ

ព្រះតេជៈព្រះគុណសុធម្មាធិបតី ស្ដីទីសង្ឃនាយក វត្តបទុមវតី

ព្រះតេជព្រះគុណកស្សប

ព្រះតេជព្រះគុណព្រះមុនីកោសល

ព្រះតេជៈព្រះគុណព្រះឃោសធម្ម នឹងព្រះថេរានុថេរគ្រប់ព្រះអង្គ, សូមអភ័យទោស ដោយខ្ញុំព្រះករុណាពុំបានបញ្ចេញព្រះនាមសព្វគ្រប់ ៗ

សូមពរមេត្តាប្រោស, ខ្ញុំព្រះករុណាសូមថ្លែងសង្វេគប្បកាសដែលមានតទៅនេះ

សង្វេគប្បកាស

សូមប្រកាសជូនដំណឹង ចំពោះក្រុមសិស្សានុសិស្ស បព្វជិត គ្រហស្ថ អស់លោកអ្នក ឧបាសក ឧបាសិកា ដែលបាននិមន្ត-អញ្ជើញមកធ្វើបុណ្យកតញ្ញូតាក្នុងទីនេះ ប្រគេន ចំពោះសម្ដេច..

សូមជ្រាប ៗ

ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងសេចក្ដីអំណរទទួលបដិការៈគុណដែលប្រកបទៅដោយសោមនស្សរបស់អស់លោក-អ្នកទាំងឡាយ ជាជំនួសសម្ដេចតាមសំរេចគប្ប-

កាសជាអនុស្សាវរណីរាំង   របស់សម្ដេចដែលមានសេចក្ដីដូចតទៅនេះ

អស់លោក-អ្នក បព្វជិត គ្រហស្ថ ទាំងឡាយ !

កាលដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ព្រះអង្គទ្រង់ចូលបរមនិព្វានទៅបាន ២៤៩៩ ឆ្នាំនេះហើយ ខាងលើនៃឆ្នាំដែលទ្រង់ចូលនិព្វាននោះ ជាកាលឆ្នាំដែលព្រះអង្គគង់ធរមាននៅ ព្រោះព្រះអង្គមានព្រះជន្មាយុបាន៨០ឆ្នាំប៉ុណ្ណោះ,(១) រវាង៨០ឆ្នាំទ្រង់បានសំដែងធម៌ទេសនាណែនាំប្រជាជនសម័យនោះ ជាផ្លូវការរបស់សាសនា ទ្រង់បានបំភ្លឺប្រជានិករ ឲ្យស្គាល់យល់ច្បាស់ ឃើញជាក់ផ្លូវ ទុក្ខធម៌ដែលជាសភាវពិត ជាសភាវទៀងទាត់ ជាសភាវមិនប្រែប្រួលទៅជាសភាវដទៃ ដែលជាសភាវមានដំណើរធ្លាក់ចំមកលើរូបប្រជានិករគ្រប់ឋានៈជាអ្នកទទួលរង ហើយទ្រង់បានប្រាប់លក្ខណគ្រឿងកត់សំគាល់របស់រូប ដែលព្រឹត្តិការណ៍គួរដល់ការបាក់បែកទ្រុឌទ្រោមវិនាសទៅដោយរបៀបលក្ខណធម្មជាតិ មានក្ដៅនឹងត្រជាក់ណាស់ជាដើម ព្រោះថា រូបនេះមានបូរណភាពសម្បូរសម្បូណ៌កកកុញទៅដោយរោគភាព ដែលចូលទៅជ្រកកោននៅអាស្រ័យ ជាបច្ច័យញាក់ញីញ្ញើរ ឈ្មួចដះដាន់ ជីវភាពរបស់រូបនោះ ឲ្យអន់ខ្សោយថយចុះតាមលំដាប់ថ្ងៃ ខែ ឆ្នាំតទៅទល់គ្នានឹងវិនាស ។ កាលបើរូបនេះជាទុព្វលហើយ ការប្រយុទ្ធតស៊ូនឹងរោគភាពមិនឈ្នះហើយ សកម្មភាពរបស់រូបនោះនឹងប្រព្រឹត្តទៅដូចម្ដេចហ្ន៎ ! គួរបាត់ទៅតាមផ្លូវណា ? អើ ! បើដូចហ្នឹង ! រូបមានរោគភាពធ្វើឲ្យដម្បៅឈឺចាប់នេះ គួរបាត់កន្ទុរូបសភាពក្រ ដូចមនុស្សក្រទ្រព្យសម្បត្តិនោះដែរៗ មិចក៏បាត់ជាសភាពក្រ ? ព្រោះថារោគភាពនោះ វាបំផ្លាញជីវភាពដែលជាដួងកែវព្រលឹង

(១) មតិខ្លះយល់ថា ព្រះអង្គមានព្រះជន្ម ត្រឹម ៨០ មិនដល់កម្រិត ១០០ ឆ្នាំព្រោះនឿយហត់ពេកមានការណីយកិច្ចច្រើន ចំពោះប្រជាជន (មនុស្សធ្វើការច្រើនប្លាសកម្រិតអាយុខ្លី)

របស់មនុស្សដែលកំពុងតែរស់នៅដោយសេចក្ដីសុខសប្បាយ វាធ្វើឲ្យអន្តរាយហិនហោច បាត់បង់ការមានការបានរបស់ជីវភាព ដែលជាសុខស្រួលរស់នៅនោះ ត្រឡប់ត្រឡិន បង្វែងជានឲ្យខានបាន លែងមានអ្វីតទៅមុខទៀត ធ្លាក់ទៅជាសភាពក្រ មិនងាយនឹងមានបានជីវភាពរស់នៅស្រួលនោះទេ ។ នេះហើយហៅថា ទុក្ខធម៌ មិនប្រែប្រួលទៅតាមសភាពដទៃ, ដល់ម្លឹងតើ! គួរឲ្យនឹកស្ដាយដល់ជីវភាព របស់ប្រជាជនប្រុសស្រី ដែលតែងតែស្រឡាញ់ស្នេហាប្រាថ្នាចង់ឲ្យបានមានសុខភាព រស់នៅអស់កាលយូរតអង្វែងទៅ តែពុំសូវបានគាប់សមតាមបំណងដែលប្រាថ្នានោះសោះ បែរជាទុក្ខធម៌គ្រលុកអុកនៅជាប់ស្អិតក្នុងចិន្ដាគេយើងទាំងអស់គ្នា ។ ព្រះពុទ្ធដីកាត្រាស់ថា „បើរូបនេះជាអនត្ដាខ្លួនប្រាណមែន„ រូបនេះមិនប្រព្រឹត្ដទៅដើម្បីជម្ងឺអាពាធទេ ព្រោះរូបនេះមិនមែនអនត្ដាហើយបានជាឈឺ គឺរូបនេះជាអនត្ដាមិនមែនខ្លួនយើងគេ បានជាជម្ងឺមេរោគចូលគ្រលុកនៅពេញក្នុងរូបនេះកើត „ ។

ប្រកាសសេចក្ដីប៉ុណ្ណោះ ដើម្បីសម្រាលសម្រន់សេចក្ដីទុក្ខព្រួយក្រុមសិស្សានុសិស្ស ព្រមទាំងអស់លោក-អ្នកសប្បុរសទាំងឡាយ ដែលមានសន្ដានចិត្ដមេត្រីភាព ចំពោះខ្ញុំករុណា អាត្មាភាព ហើយបានព្រួតដៃគ្នាតយុទ្ធប្រយុទ្ធនឹងរោគនេះ ដោយថ្នាំឱសថយ៉ាងចំណាន ផ្ចាលផ្ចាញ់រោគនេះឲ្យអន់ទន់កម្លាំងរាថយក្រោយដោយអំណាចព្យាបាលទាល់តែរោគនេះរសាយដៃ ធ្វើឲ្យអត្តភាព ខ្ញុំករុណាអាត្មា បានស្រួលបន្ដិចនេះឡើង ។

(នៅមាន ត)

# ស្ថានការណ៍នៅសហភាពភូមា (ត)

ម្យ៉ាងទៀត គេខំដែលឃើញបុគ្គលរូបណា ទោះមានបុណ្យសក្តិក្តី ទ្រព្យសម្បត្តិក្តី ឬក៏មានសមត្ថភាពបែបណាក្តី គ្របសង្កត់បុគ្គលណា នោះគ្មានយសសក្តិក្តី កោតសម្បត្តិក្តី ដោយពលក្ការណាមួយបានឡើយ ស្រេចហើយនៅលើការខុសត្រូវ ស្រេចលើច្បាប់ គឺគេតាំងទុកប្រជាជនគ្រប់រូប មានសិទ្ធិនិងសេរីភាពស្មើគ្នាទាំងអស់ តែសេចក្តីគោរព បំពោះគុណធម៌និងសីលធម៌ផ្សេងៗ ការលំទតលំទុនក្តី ការលំទោនកាយ-វាចា-ចិត្តទៅវិញទៅមកក្តី គេនិយមប្រើជានិច្ចនិវត្តិ៍ ហាក់ដូចជាបុគ្គលមានសមានុភាពជាដរាប ។

១០ – ករណីយកិច្ចនៃកុមារ កុមារី៖ បណ្តាកុមារ កុមារីទាំងឡាយ កាលបើដឹងក្តីអាយុ ៥.៦.៧ ឆ្នាំឡើងទៅ ត្រូវតែឲ្យចូលទៅរៀន បំពោះវិជ្ជាក្នុងសាលារៀន ជាអាចិន្ត្រៃយ៍ ។ ដូច្នោះកុមារ-កុមារី ពុំសូវមានសល់ទំនេរ ឯគេហស្ថានអសារឥតការទេ ទាំងមិនបានបណ្តែតបណ្តោយក្មេងតូចធំ ឲ្យលេងល្បែងផ្តេសផ្តាសឥតប្រយោជន៍ ដូចជា បាយឡុកបាយឡ បាយយំ ប្អូនពំនូតដី ជាដើមឡើយ ។ ១ទៀត បំពោះកុមារ-កុមារីទាំងឡាយ ឪពុក-ច្រើនតែបង្ហាត់បង្ហាញឲ្យរៀនកំ ឲ្យប្រៀង ព្រោះហេតុនោះ នៅសហភាពភូមា កុមារ-កុមារី ដែលមានវ័យវឌ្ឍនាការរវាង ៥.៦.៧.៨. ឆ្នាំឡើងទៅ អាចរាំបាក់ក្បាច់យ៉ាងទន្ទាំ ហាក់ដូចជា មនុស្សកម្លោះក្រមុំដែរ ។ បានជាក្នុងពេលដែលមានបុណ្យធំៗម្តងៗដូចជាបុណ្យចូលឆ្នាំក្តី បុណ្យចូលចេញព្រះវស្សាក្តី ឬក៏ពិធីបុណ្យអ្វីផ្សេងៗក្តី គេតែងជួបប្រទះកុមារនិងកុមារីទាំងឡាយ ប្រមូលគ្នាជាពួកជាក្រុមក្នុង១ពួកៗ ៣០ នាក់ឬ៤០នាក់ ស្លៀកពាក់ជាឯកសណ្ឋាន ឈរ-ដើរជាជួរៗ ឬក៏ជាវង់ជុំកង់ ប្រែកប្រៀង របាំទះដៃបាក់ក្បាច់យ៉ាងទន្ទាំ គួរឲ្យនឹកសើច

គោតសរសើរ ដល់ការអប់រំជាតិគេពន់ពេក ៗ មិនតែប៉ុណ្ណោះ នៅពេលដែលមានការប្រជុំធំៗម្ដងៗគេឃើញកុមារ កុមារីទាំងឡាយ ចាប់កាន់ៗគ្រឿងសក្ការ ថ្លែងការណ៍ យ៉ាងអង់អាច ជាការហាត់សតិបញ្ញាឲ្យក្លាហានឲ្យថ្នឹកដំនាញ ក្នុងការថ្លែងការណ៍ ការបរបារពិភាក្សាកិច្ចការផ្សេងៗ កុំឲ្យតក់ស្លុតខ្លាចញញើតញញើរប្លុកអើតអើម ក្នុងទីប្រជុំជន ៗ ការប្រៀនប្រដៅការហ្វឹកហ្វឺន ការហាត់ពត់ក្មេងៗ តាំងពីតូចៗ យ៉ាងនេះ លុះត្រាដល់វ័យចំរើនធំឡើង ប្រាកដជាមានសមត្ថភាពនឹងប្រតិពលពិតមែន សមដូចជាបុរាណសុភាសិតថា « ចេះដប់ពុំស្មើប្រសប់ម្នាក់ » រៀនចេះដឹងពិតមែនតែពុំថ្នឹកដំនាញ ពុំដែលចូលកាន់ទីប្រជុំ ពុំដែលហ្វឹកហ្វឺន គ្មាននរណាពន្យល់ណែនាំដោយកិច្ចបញ្ញាថា « ត្រូវធ្វើយ៉ាងនេះ យ៉ាងនោះជាដើម ក៏ពុំបានការឡើយ ។

ន័យ ១ ទៀត ប្រជាជនភូមា និយមយកជើងជាប្រមាណ ខុសពីប្រជាជនខ្មែរយើង យើងនិយមយកក្បាលជាប្រមាណ ។ គឺថាក្នុងកាលដែលចូលទៅកាន់ទីសមាគមក្ដី ទីអារាម ទីព្រះស្តូប ចេតិយក្ដី ពុំគិតដល់ការអង្គុយទេ ក្បាលនៅតែពាក់កន្ដប ឬ ជួតឈ្នួតធម្មតា តែស្បែកជើងត្រូវតែដោះជាដរាប ៗ ពួកជនខ្លះដែលត្រូវការចូលទៅកាន់ វត្តអារាម ឬ ទីលានព្រះស្តូបចេតិយ ត្រូវដោះស្បែកជើងកាន់ដើរជានិច្ច ។ ឯការអង្គុយទៀតសោត បើទុកជាក្នុងទីចំណោមអ្នកមុខអ្នកការក្ដី ទោះព្រះក្រ្តព្រះភិក្ខុសង្ឃក្ដី ទោះមុខនាម៉ឺនសព្វមុខមន្ត្រីក្ដី ច្រើនតែអង្គុយពែនភ្នែន ព្រោះគេយល់ថា ការអង្គុយពែនភ្នែន ជាឥរិយាបថស្រួល ១ បែប នឹងការឆាយផង ៗ បើភិក្ខុ-សាមណេរ ទោះបីចូលទៅក្នុងទីប្រជុំណាក៏ដោយ ត្រូវតែគង់ពែនភ្នែនជាដរាប ព្រោះឥរិយាបថនេះល្អ អង្គុយទៅតម្រង់គ្រាំងកាយបានស្រួល មិនបទបែនពង

កាយ ខ្យល់ចេញ-ចូលបានដោយងាយ ។ ការពោលមកនេះចំពោះតែបុរសតែទទេ ឯស្ត្រីគេទុកផ្គុំយបត់ដើរដូចជាស្ត្រីនៅប្រទេសខ្មែរយើងដែរ ។

១១– អំពីការបង្កើតសមាគមៈ នៅសហភាពភូមា គេបានបង្កើតសមាគមច្រើនយ៉ាងណាស់ ដូចជាសមាគមការសិក្សាសមាគមបកប្រែភាសាជាដើម ។ សមាគមការសិក្សា គឺគេបង្កើតសមាគមទបត្ថម្ភការសិក្សា គម្ពីរ ក្បួនច្បាប់ផ្នែកខាងព្រះពុទ្ធសា-សនាមានការសិក្សាមូលវេយ្យាករណ៍ ប្រសូត្រ វិន័យ (គហិវិន័យ) និងអភិធម្ម ។ សមាគមនេះមាន ២ ផ្នែកៈ ផ្នែកទី ១ សម្រាប់បុរស, ផ្នែកទី ២ សម្រាប់ស្ត្រី, កាលបរិច្ឆេទដែលត្រូវរៀនកំណត់ ៣ ឆ្នាំក៏មាន ៥ ឆ្នាំក៏មាន ។ល។ ព្រោះហេតុនោះបានជា ប្រជាជនភូមា ភាគច្រើនទាំងបុរសទាំងស្ត្រី ចេះតែងបាលី បកប្រែភាសាបាលីមកជាភាសាភូមា ព្រមទាំងចេះនិយាយភាសាបាលីប្រាស្រ័យការជាផ្លូវការល្មមគួរសមបានផង ។ សមាគមបកប្រែភាសាៈ គេបានបង្កើតសមាគមបកប្រែភាសា គឺប្រែភាសាបាលីទៅជាភាសាភូមា, ពីភាសាភូមាទៅជាភាសាអង់គ្លេស-បារាំង, ពីភាសាអង់គ្លេស-បារាំងទៅជាភាសាភូមា, ពីភាសាបាលីទៅជាភាអង់គ្លេសចងក្រងជាសៀវភៅក្បួនខ្នាត សម្រាប់ឲ្យពលរដ្ឋគេសិក្សាតាមលំដាប់ថ្នាក់ ទីងលំដាប់ឆ្នាំយ៉ាងសម្បូរពុំសូវខ្វះខាត ។ អ្នកដែលធ្វើការនោះ ៗ ច្រើនតែមន្ត្រីចាស់ ៗ ដែលផុតដំណែងក្នុងក្រសួងនានា ហើយមានបំណងចង់ធ្វើសាធារណប្រយោជន៍ដ៏សំខាន់ដល់ប្រទេសដល់ពលរដ្ឋទូទៅ ។ ហេតុដូច្នេះហើយបានជាប្រទេសគេ សម្បូរកុះករដោយក្បួនខ្នាតជាសៀវភៅមើលដូចជាទស្សនាវដ្ដី រឿងប្រលោមលោក សៀវភៅសម្រាប់សិក្សាអក្សរសាស្ត្រផ្សេង ៗ ជាដើម ។ សិក្ខាតាម អ្នកដែលត្រូវការសិក្សាបំណេះ

វិជ្ជាផ្សេងៗ ផ្នែកខាងអក្សរសាស្ត្រប្រចាំជាតិគេក្តី អក្សរសាស្ត្របរទេសមានភាសាអង់គ្លេសក្តី ងាយស្វែងរកសៀវភៅក្បួនខ្នាត ងាយសិក្សា ឆាប់បេះដូងមិនសូវតឹងគំនិតពេក ៗ នៅប្រទេសខ្មែរយើង មានអ្នកចេះដឹងភាសាបរទេសច្រើនគ្នាណាស់ ប៉ុន្តែនៅខ្វះខាតក្បួនខ្នាត ៗ ដែលប្រែចេញពីភាសានានាមានភាសាបារាំងជាដើម ពុំគ្រប់គ្រាន់ដល់ការសិក្សាសោះ នេះជាវាសនានៃសិក្ខាកាមនៃកុមារ-កុមារីទាំងឡាយ ដែលជាពលរដ្ឋខ្មែរជាន់ក្រោយ ៗ

១២– អំពី សមាគមកុមារសង្គ្រោះ នៅប្រទេសភូមាមានបង្កើតសមាគមកុមារសង្គ្រោះ គឺបង្កើតគ្រោងការណ៍ ដើម្បីជាជំនួយជួយឧបត្ថម្ភដល់ការខ្វះខាតនៃកុមារកុមារីទាំងឡាយដែលជាអ្នកទីទ័លក្រ មានឪពុក-ម្តាយក្តី ឥតឪពុក-ម្តាយក្តី ឲ្យមានការសិក្សា មានគ្រឿងប្រដាប់ប្រើប្រាស់ល្មមគ្រប់គ្រាន់ប្រពៃលទងសមាគមកុមារសង្គ្រោះនៅប្រទេសខ្មែរ ដែលកើតឡើងដោយសារស្នាព្រះហស្តនៃព្រះសម្តេចព្រះឧបយុវរាជ ន. សីហនុ ទ្រង់បង្កើតឡើងដែរ ៗ ពិតមែនតែសមាគមគេ ស្ថិតនៅក្នុងអធិបតីភាពនៃរដ្ឋាភិបាល តែពលរដ្ឋនៅប្រទេសគេ គឺពួកអ្នកមានធនធានច្រើន ៗ តែងជួយផ្តល់ភោគទ្រព្យផ្សេងៗ មានប្រាក់កាស សំលៀកបំពាក់ និងគ្រឿងប្រើប្រាស់ផ្សេង ៗ ជាជំនួយដល់រដ្ឋាភិបាលគេដោយច្រើន ៗ ព្រោះគេយល់ថាកិច្ចនេះជាបុណ្យកុសលដល់ជនទូទៅដែរ ៗ មិនតែប៉ុណ្ណោះសោត រដ្ឋាភិបាលបានបង្កើតសាលា ១ ផ្នែកហៅថា “សាលាអនុបាល” សាលានោះរាជការបង្កើតឡើង ដើម្បីបង្ហាត់បង្រៀន ប្រជាជនដែលមានភ្នែកខ្វាក់ ឬក៏ងងិតធ្វើការអ្វីពុំកើត អនាថាឥតទីពឹង ៗ

(នៅមានត)

## វិចារណកថា (ត)

គ្រាន់តែបបួលគ្នាបំពេញករណីយកិច្ចមួយបែបរបស់ខ្លួនដែលជាសិស្ស ហើយក៏មិនបាននាំគ្នាពពាក់ពពូន ដើរជាពួកជាក្រុម ឈ្លបុះ ធឡើង សម្ដែងរិទ្ធិ សំឡុតបំភ័យឲ្យគេឯងព្រមតាមបំណងរបស់ខ្លួនឡើយ ។ ការធ្វើនេះ ក៏ពុំឃើញមានផ្ទុយខ្លាំងនឹងពុទ្ធភាសិតប៉ុន្មានដែរ ។

ដើម្បីសេចក្ដីចំរើន នឹងពន្លឺដំហរអនាគតនៃព្រះពុទ្ធសាសនា ក៏គួរតែយើងអបស្ងុបចិត្តនៃសមណនិស្សិតទាំងនោះខ្លះផង កុំបបួលគ្នាយកកំហុសទាំងស្រុង មកសង្កត់លើគេ ដែលជាទីគោរពរបស់យើងយ៉ាងនេះ ។

ជាយូរមកហើយ ប្រទេសយើងតែងគោរពលើគោលសំខាន់បីយ៉ាង គឺ ជាតិ សាសនា-មហាក្សត្រ ។ ក្នុងគោលទាំងបីនេះ យើងឃើញសាសនា ជាស្នូលនៃជាតិ នឹងព្រះមហាក្សត្រ វប្បធម៌ អារ្យធម៌ សីលធម៌ ក៏សុទ្ធតែផ្សាយចេញអំពីផ្លែនៃសាសនាទាំងអស់ ។ នៅប្រទេសណាក៏ដោយ បើគេឃើញអ្នកកាន់សាសនាផ្ទាល់ច្រលច្របល់ដោយហេតុអ្វីមួយ ក៏គេត្រូវតែចូលទៅគោរព ហើយសាកសួរ ដើម្បីយុត្តិធម៌ចំពោះរឿងនោះតែម្ដង ។ គេមិនដែលពាក់មុខយក្ស ហើយទំលាក់ទោសទាំងស្រុង ទៅលើគេជាទីគោរពទាំងនោះទេ ។ មិនតែប៉ុណ្ណោះ ពាក្យបចាមអាក្រមទាំងឡាយ ក៏បានសាយភាយទួទៅទាំងប្រទេសថា: "ឲ្យបាយលោកសង្ឃទាំងអស់នោះស៊ីឆ្អែត បើវាបបួលគ្នាធ្វើកូដកម្មដូចជា បាសកដែរនោះ„ អើវាដូចជាជ្រុលហួសបន្តិចទៅហើយ សំដីនេះ យើងឮហើយយើងថា ក៏មិនខុសគ្នាអំពីយើងផឹកស្រា ហើយយើងដេរគេដែរ ។

ព្រះសង្ឃរស់នៅដោយកម្លាំងស្ន ហើយសិក្សាច្បាប់ព្រះពុទ្ធសាសនា ដើម្បីប្រយោជន៍អនាគតរបស់ប្រទេស នឹងសន្តិភាពលោកទាំងមូល តែទោះបីដូចម្តេចក៏ដោយ សមណនិស្សិតទាំងនោះ ក៏គង់តែមានថ្ងៃណាមួយ ទៅជាគ្រហស្ថដូចគេឯងពលគ្នាដែរ ចុះបើជីវភាពអនាគត នៃគ្រហស្ថដែលទើបតែនឹងផ្លាស់ភេទពីបព្វជិតមិនមានការថ្លៃថ្នូរ ដូចគេឯងពលគ្នាទៅហើយ តើការគោរពនឹងលើកស្ទួយព្រះពុទ្ធ-សាសនា តាមកម្លាំងនៃជនដ៏ខ្សត់ខ្សោយបែបនោះ នឹងមានសភាពយ៉ាងណាទៅវិញ ។

បើយើងងាកមកនិយាយអំពីគ្រហស្ថជានិស្សិតវិញ ការរស់នៅរបស់និស្សិតដំបូកនោះ ក៏គោងអាស្រ័យកម្លាំងជាតិទាំងស្រុង បាយទឹក ទីសិក្សា ដំណែងសព្វយ៉ាង ក៏ជាតិឲ្យទាំងអស់ ចុះក្នុងពេលដែលក្រុមនោះ បានធ្វើកូដកម្មប្រឆាំងនឹងជាតិវិញ ដោយយកកម្លាំងទាំងស្រង ទៅបំពានឥតត្រាប្រណី នោះតើយើងថាដូចម្តេច?

ឱ វាសនាខ្មែរ! អ៊ូហ្ន៎! ក៏នៅតែប្រឡូបល់យ៉ាងនេះ ពេលណា ហ្ន៎! ដែលឲ្យខ្មែរបេះស្រឡាញ់គ្នា បេះរក្សាភេទ ហើយចាប់ដៃគ្នា កសាងប្រទេសទៅអនាគត បើខ្មែរនៅតែបែកគ្នា ហើយឲ្យខុសដល់គ្នានឹងគ្នាយ៉ាងនេះ ។

សេចក្តីពណ៌នាទាំងប៉ុន្មាន ដែលខ្ញុំបានពោលរៀបរាប់រួចមកហើយ ក៏គ្រាន់តែសរឲ្យឃើញថា យើងមិនទាន់មានយុត្តិធម៌ក្នុងការរួមរស់ជាមួយគ្នានៅឡើយ ដោយខ្មែរនៅតែបំភេងស្វាប ពោលអួត ថាអញ! ថាមានតែអញ! ជាដើម ។

នឹងឲ្យរឿងនេះផុតការស្មុគស្មាញមែនទែន លុះណាតែបង្កើតបទបញ្ញត្តិមួយក្តាមដោយហាមផ្តាច់ ដល់សមណៈ ដែលចូលមកសិក្សាក្នុងវិទ្យាល័យព្រះសុរាម្រិតក្តី ក្នុងមហាវិទ្យាល័យព្រះសីហនុរាជក្តី ឲ្យផុតសិទ្ធិពីការលាចេញចាកភេទមកជាឧបាសក

វៀរលែងតែក្នុងករណីចាំបាច់ណាមួយ ដែលច្បាប់សាសនាបានតម្រូវ ថាត្រូវឲ្យចាកចេញជាគ្រហស្ថ ។

មុននឹងបញ្ចប់ ខ្ញុំសូមលើកករទាំងដប់ខមាទោស ដល់ព្រះសង្ឃគ្រប់ឋានៈ ចំពោះរាជរដ្ឋាភិបាលឲ្យជួយបំភ្លឺ រឿងរ៉ាវទាំងនេះផង ហើយសូមកុំភ្លេចថា ខ្មែររស់នៅជាមួយនឹងជាតិ សាសនា ព្រះមហាក្សត្រ ។

ជយោ ព្រះពុទ្ធសាសនា!

បណ្ណាធិការ

---

## បុណ្យរំលឹកព្រះពុទ្ធសាសនាគំរប់ ២.៥០០ព្រះវស្សានៃប្រទេសកម្ពុជា(តបប់)

បើតាមពុទ្ធទំនាយថា នរណារស់នៅទាន់ ២.៥០០ ព្រះវស្សានោះ អ្នកនោះនឹងមានសំណាងខ្ពង់ខ្ពស់, នោះបីនឹងច្យុតទៅភពណាក៏មិនជោគតាបដែរ ។ សេចក្តីត្រង់ណេះ បើពិចារណាតាមផ្លូវធម៌នឹងឃើញមានសេចក្តីពិតច្រើន ព្រោះថាអ្នករស់នៅទាំងឡាយអាចបានធ្វើបុណ្យទាន់ពិធីនេះហើយ មានចិត្តកើតសង្វេគ នឹងកើតក្តីរីក-រាយយ៉ាងខ្លាំងកាលដែលឃើញព្រះពុទ្ធសាសនាមានជ័យមកដល់ ២.៥០០ ឆ្នាំដោយគាត់ឆ្លងឧបសគ្គរាប់ពាន់ម៉ឺនយ៉ាងមកបានដោយស្រួល ។

យើងដឹងស្រាប់ហើយមុន ២.៥០០ ឆ្នាំនេះជីវិតយើងកល់គ្នា សុទ្ធតែត្រូវរាំងយ៉ាងខ្លាំង ទាំងអ្នកល្ងង់អ្នកចេះច្រើនតែស្លាប់ ។ ឃើញនៅរស់តែពួកអ្នកណា ដែលដឹងទាន់គំនិតប្រាជ្ញារបស់សត្រូវទេ ។ ពេលមុននេះមានចោរហារយ មានជម្ងឺកក្លែងក្លាយ បាននាំគ្នាបង្ហិលខួរក្បាលមនុស្សឲ្យវិល ឲ្យខូចខ្លួនឲ្យបង់នូវជីពជន្ម គួរឲ្យស្តាយជាបំផុតតែរហូតសន្និយាយទៅហើយ ព្រោះជាកម្មរបស់សត្វលោក ។ ចំណែកឯព្រះ

ធម្មវិន័យ សោតយើងក៏ដឹងដែរថា មានជួបប្រទះនឹងឧបសគ្គជាច្រើនអនេក គឺមាន ពាហិរសាសនាចូលមកលុកលុយ ហើយមានជួនកាលគេហ៊ានទាំងទំលាយវត្តអារាម នឹងព្រះសង្ឃដែលកាន់ព្រះពុទ្ធសាសនាផង ដើម្បីឲ្យសាសនាវិនាសអន្តរាយ តែគេធ្វើណាស់ព្រះពុទ្ធសាសនារិតតែមានអានុភាពណាស់ ព្រោះសច្ចធម៌មិនដែលស្លាប់ ដូចពុទ្ធភាសិតថា សច្ចំវេ អមតាវាចា (ពាក្យពិតមិនស្លាប់) នឹងពុទ្ធភាសិតមួយទៀតថា សតញ្ច ធម្មោ នជរំ ឧបេតិ (ធម៌របស់សប្បុរសមិនចេះចាស់ជរា) ។ គួរឲ្យអស្ចារ្យណាស់ព្រះពុទ្ធសាសនានេះ បើគ្មានសច្ចទេ ម៉្លេះសមពាហិរសាសនាទំលាយសាប់សូន្យហើយ នេះមិនដូច្នោះ គឺត្រឡប់ជាមានជ័យជំនះឈ្នះពាក្យមិនសច្ច ឈ្នះពាក្យដែលគ្មានពុទ្ធប្រាជ្ញាយ៉ាងស្អាតបែសដរាបគ្រប់ ២.៥១០ឆ្នាំ នៅតែមានរស្មីគួរឲ្យរំភើបរកអ្វីប្រៀបពុំបាន ។

យើងរាល់គ្នាគួរហើយ ដែលនឹងធ្វើបុណ្យខួប២.៥០០ព្រះវស្សានេះ ។ ឲ្យយ៉ាងឧឡារិក ដើម្បីទុកនូវគំនរបុណ្យដែលយើងធ្វើនៅពេលនេះ ជាអនុស្សតិរបស់យើងដរាបដល់យើងរលត់ជីវិតរៀងខ្លួន ។

មួយទៀតប្រទេសយើង ដែលបានឯករាជ្យពេញទីនេះ គឺមានព្រះដ៏មានបុណ្យមួយអង្គ បានដល់សម្ដេចព្រះនរោត្តម សីហានុ ឧបយុវរាជ ដែលព្រះអង្គទ្រង់រំដោះទុក្ខយើង នាំយើងឲ្យរស់រានមានជីវិតបានសន្តិភាពជាស្ថាពរ ដូច្នេះយើងគួរតែខំធ្វើបុណ្យធ្វើទានរក្សាសីលរក្សាសត្យគ្រាន់នឹងរស់នៅតទៅទៀត បានជាគុណព្រះបារមីនៃព្រះអង្គ ។ យើងមានព្រះបរិយាសម្មាបដិបត្តិ ដូចជាព្រះបាទធម្មិក ដែលយើងធ្លាប់ដឹងពុទ្ធទំនាយ ។

សម្តេចព្រះឧបយុវរាជនេះក្រៅពីទ្រង់មានព្រះបរិយាល្អហើយ ព្រះអង្គទ្រង់មានព្រះឧស្សាហ៍ចិត្ត ហើយមានព្រះកាយជាទីស្នេហា នៃអ្នកដែលបានឃើញថែមទៀត ។ ព្រះអង្គអាចទំលុះទំលាយបញ្ហា ដែលជាអាយុជីវិតនៃប្រទេសជាតិឲ្យរួចផុតពីអន្តរាយពប់មិនឈ្នះ កាលទ្រង់យាងទៅកាន់ទីណា, ប្រទេសណាព្រះអង្គតែងមានជោគជ័យជាដរាប ។

សូមជ្រាបដោយសង្ខេបទៀតថា តាំងពីព.ស.២.៥០០ដល់២.៥០៧ព្រះវស្សានៅមានវាលមួយធំសំរាប់យើង ដែលយើងរាល់គ្នាមិនគួរធ្វេសប្រហែសទេ ។ តាមពុទ្ធទំនាយថាមនុស្សដែលរស់នៅទាន់ ២ ៥០០ ព្រះវស្សានោះ បើគេប្រព្រឹត្តធម៌ ៣ យ៉ាង គឺ ១– មិនប្រមាទឪពុកម្ដាយរំលាយព្រះ, ២. មិនលួចប្លន់ទ្រព្យសម្បត្តិគេ. ៣. មិនសម្លាប់សត្វបំបាត់ជីវិត ហើយធ្វើទានរក្សាសីលឲ្យបរិសុទ្ធ, អ្នកនោះនឹងបានសេចក្ដីសុខចំរើន ព្រោះគេទៅមុខមានទំនាយថា នឹងដុះភ្នំមាស, ប្រាក់, កែវកង ពិទូរ្យសូរិកាន្ត ហើយគ្រប់រូបនឹងគ្មានរោគាព្យាធិ គឺដល់ពេលមរណៈក៏ស្លាប់ទៅតាមអាយុខ័យរបស់ខ្លួន ។

គួរឲ្យយល់ថាប្រហែលជានឹងដុះរបស់នេះមែន ព្រោះតាំងពីឥឡូវនេះទៅ យើងក៏ឃើញព្រាងៗហើយថា គ្រាន់តែគ្រោងការណ៍ពីរឆ្នាំ ទីកំពង់ផែនៅមាត់សមុទ្រកំពង់សោមស្ទើរតែជាភ្នំមាស–ប្រាក់ទាំងអស់ គួរកត់សំគាល់ថា ទំនប់ទឹកទាំងឡាយ អាចឲ្យខ្មែរធ្វើស្រែបានពីររដូវ ដាំដំណាំកើតផលច្រើន ហើយវត្ថុដែលកើតពីករណីនេះ នឹងត្រូវដឹកនាំតាមកំពង់សមុទ្រយើង ទៅលក់យកមាស–ប្រាក់តាមចិត្តរបស់យើង ។ មិនតែប៉ុណ្ណោះ អគ្គារអនាម័យ ក៏បានទទួលជំនួយនូវថ្នាំស័ក្តិសិទ្ធិជាច្រើនដើម្បីបំបាត់

ពេតព្យាធិ អាចទំលាយនូវពេតដែលជាតិយើងយល់ថាជាពេតមើលមិនជា ឲ្យជាទៅបាន; ឃើញថាសេចក្ដីពិតបេះតែកើតឡើងហូរហែគួរឲ្យយកជាការពិតមែន ៗ យើងសង្ឃឹមយ៉ាងមុតមាំថា ដើម្បីសិរីសួស្ដីដល់វង្សគុណញាតិ ទឹងជាតិប្រទេសរបស់ខ្លួន ៗ ហើយបណ្ណអនុស្សាវរីយ៍នៃពិធីបុណ្យឆ្លង ២.៥០០ ព្រះវស្សាដែលគណៈកម្មាធិការបោះពុម្ព មុខជាទឹងបានពុទ្ធសាសនិកជនទូទៅ ទិញយកទៅទុកជាទីរលឹកស្មារតី តាមកម្លាំងសទ្ធារៀងខ្លួនជាប្រាកដ ៗ

ចប់

---

## ពុទ្ធប្បវត្តិ

(តទៅទស្សនាវដ្ដីលេខ៥មក)

ព្រះពោធិវង្ស ស្ដាប់ពុស្សរស័ព្ទដូច្នោះហើយ ពុំមាននៅកន្ដើយ ទ្រង់ទូលឲ្យវរបិតា ៗ ត្រាស់ហៅរាជវង្ស ញាតិផៅពង្សរាជសេនា ឲ្យបូលមកត្រៀបត្រា មើលបេស្ដាថ្ងៃឯបុទ្ធី ៗ លុះដល់ជួបជុំហើយ ពុំកន្ដើយព្រះពោធិ លើកធ្នូសរត្រវី បាញ់ទោះទីសព្វទិសា ៗ ស័ព្ទសែងខ្ទរខ្ទរពៃព្រ ញ័រប្រឹបពីផែនពសុធា មានតេជៈជ័យ ឥតគណនា ទឹងប្រៀបបាន ៗ ព្រះញាតិទាំងឡាយយល់ ឥទ្ធិពលបុត្រក្សត្រកាន្ត រីករាយគ្រប់ ៗ ប្រាណ ខ្វាន់ប៉ុន្មានខ្ទបខ្ទាបដៃ ៗ ទើបព្រះញាតិវង្ស គាក់តែងអង្គនារីថ្ងៃ មានរូបឆោមឆើតក្រៃ ល្អប្រពៃវរកញ្ញា ប្អូនមុំនរូបនារី សុទ្ធសោភីពល់កាយា នាំមកថ្វាយព្រះមហាក្សត្រថ្ងៃថ្វាសោយរាជថ្មី ៗ ឯអង្គព្រះបិតា បមក្សត្រាធិបតី ទ្រង់លើកវរក្សត្រី បមទេវីនាមពិម្ពា ៗ ជាអគ្គមហេសីធំ លើស

ស្រីស្នំផងនានា ផ្សំនឹងពងបុត្រា សមសក្កាលើសលោកិយ ។ អភិសេកជាឯក អគ្គ បុទ្ធីវគ្គពេញបូណ៌មី កត្តិក-អាទិត្យខ្មី រៀបផ្លាស់ថ្មីនៃវង្ស ។ ឯឆ្នាំនោះឯង ណា មានឈ្មោះថាគឺឆ្នាំជូត ចំថ្ងៃណាស់ពេកក្រៃ ល្បីល្បាញទៅដល់ខ្ចរខ្ចាយ ។ ព្រះអង្គគង់យូរយារ នឹងពិម្ពាប្រពើតឆាយ ឥតមានភយន្តរាយ សុខសប្បាយសព្វ វេលា ។

## ព្រះពោធិសត្វទ្រង់យាងចេញទតទីសួន

ព្រះជន្មម្ភៃប្រាំបួន ចេញទតសួនស្រស់គង្គា ព្រះអង្គទ្រង់បញ្ជា ឲ្យនាយសារថី រៀបចំ ។ ទឹមរថពងអស្សពាហ៍ ជំសោភាយ៉ាងស័ក្តិសម ឡើងគង់កបមនោរម្យ បើកបរពុំឲ្យព្រួខ្ចាំង ។ ចេញពីពន្ធនិវេសន៍ ពុំមានធ្វេសជំលាំង សារថីបរទៅនាំង ត្រោះទីតាំងពងទទ្យាន ។ ទេពមួយក្លែងភេទកិន មនុស្សចាស់ជិណ្ណានៅមុខយាន ស្បែក ជ្រីវជ្រើវឈរឈាន ឃើញហើយមានបន្ទូលថា ។ នៃសារថីអ្វីឈរ មានជំហរ មិនត្រង់ណា សារថីសនីរ៉ាថា បមបេស្តាលើសិរសី ។ នេះហើយមនុស្សជក យើងពលគ្នាទាំងប្រុសស្រី ទាំងពងពក្រស្តមន្ត្រី ឥតបើបនឹងចៀសបាន ។ ស្តេច ស្តាប់ហើយគិតថា ឱ! សង្ខារពល់រូបប្រាណ ឥតមានសុខក្សេមក្សាន្ត តែងតែបាន ទុកជានិច្ច ។ ទ្រង់ព្រួយភ័យខ្លាំងណាស់ គិតក្តីចាស់មិនមានភ្លេច ត្រាស់ឲ្យបរថ គេច មួយរំពេចចូលវាំងស្ថាន ។ ថ្ងៃមួយព្រះជៀស្ឋជ័យ ចេញទតព្រៃទៀតកំសាន្ត ឃើញមនុស្សប្រួតឥតស្រាន្ត ហើយប្រះប្រាណនទៀលដី ។ សួរសារថីសព្វគ្រប់ ក៏សព្វាប់ភ័ក្ត្រមិនស្តី ឲ្យញាក់សេះលាលី មកកាន់ទីមណីសេយ្យា ។ ទ្រង់ចេញ ទៅម្តងទៀត ក៏ច្បាស់ឆ្ងៀតឃើញមនុស្ស ស្លាប់ស្តូកស្តឹងកាយា ជ្រាបហេតុការណ៍

រងរឹតភ័យ ៗ ទើបទ្រង់ត្រាស់បង្គាប់ ដោយញ័រញាប់ដល់សារថី បររថចូលវាំងវិញ ដោយព្រះទ័យភ័យអស្ចារ្យ ៗ ឯព្រះបាទសុទ្ធោទន៍ ជ្រាបហើយសោតព្រួយចិន្ដា ឲ្យស្រីស្នំក្រមការ រូបសង្ហារក្មេងល្មមវៃ ៗ នឹងស្រីរបាំផង ដែលទន្ទ្វងឈ្លាស វាងវៃ ប្រគំច្រៀងបំរើ បំពេរលោមប្រឡែង ៗ ប្រឡប់បង្វែងចិត្ត ឲ្យបាន ស្និទ្ធស្និតអង្វែង ដោយស្ដេចស្ដាប់ជាក់ស្ដែង ប្រយោជន៍ក្រែងបាត់រំខាន ៗ ថ្ងៃមួយពន្យពោធី ប្រើសារថីដែលបំណាន ទឹមរថរំពេចបាន ស្ដេចយាងក្ដានដូច កាលមុន ៗ ចេញចាកនិវេសន៍វាំង ដំណាំងសេះសឹងលុន លឿនលយដល់ទីមុន ឃើញអ្នកបុណ្យភេទបព្វជិត ៗ ទើបមានបន្ទូលវិញ នៃសារថីស្ដីឲ្យពិត មនុស្សអ្វី អ្នកសាងព្រឹទ្ធ ពិនិត្យមើលទៅគួរជ្រះថ្លា ៗ សារថីទូលតបស្នង មនុស្សនេះហោង ឃើញភ័យណា ហើយលះបុត្រ-ភរិយា ស្វែងសុខាបំរុងប្រាណ គេទបួសខ្ពស់ប្រ ពៃ នៅក្នុងព្រៃជាទីស្ថាន ដឹងធម៌ក្នុងសន្ដាន ទឹងបានសុខសិវាល័យ ៗ ស្ដេច ស្ដាប់ព្រួយទ័យា ថាបព្វជ្ជាស្រួលពេកក្រៃ គេទនេះទើបប្រពៃ អញកែខែបួសឲ្យបានៗ ទ្រង់គិតស្រេចកាលណា ហើយយាត្រាទៅឧទ្យាន ស្រង់វារីដលដ្ឋាន ទ្រង់ក្សេម ក្សាន្តឥតមានហ្មង ៗ គង់ឧទ្យានមួយយប់ ព្រះមេភពទឹកប៉ុនប៉ង តែងអង្គដោយ គ្រឿងផង សង្ហារកងក្បាច់រចនា ៗ វិស្សកម្មទេវបុត្រ ឆាប់បំផុតក្នុងកាយា យកគ្រឿងទិព្វថ្លៃថ្លា ក្លាយក្សត្រាល្អប្រពៃ ៗ ស្ដេចជ្រាបហេតុចំហុត គឺទេវបុត្រ មិនដទៃ ស្ថិតនៅសួគ៌ាល័យ មកបំក្លែងជាមនុស្សា ៗ គ្រោះគ្រឿងអម្ពរណ៍ស្រស់ ទិព្វសម្ផស្សគួរស្នេហា ផ្សព្វផ្សាយកាយនាថា ប្លែកធម្មតាគ្រាសព្វដង ៗ

## ព្រះនាងពិម្ពាទ្រង់ប្រសូត្របុត្រ

ថ្ងៃនពីពិម្ពាស្រី អគ្គមហេសីព្រះប្យាស់ប្យន៍ ប្រសូត្របុត្រឥតហ្មង ថ្ងៃនោះ រហានឥតមោះម៉យ ៗ ទើបព្រះពុទ្ធបិតា ប្រើអមច្ចរត់ឆាប់រៃ ទៅទូលក្សត្រ ជៀស្ដច័យ នៅក្នុងព្រៃព្រឹក្សសាន្ត ៗ អាមាត្យទូលរាជសាសន៍ រត់រហ័សចេញទៅ ក្ឋាន ដល់ហើយក្រាបក្រញូវប្រាណ ទូលក្សត្រក្សាន្តសព្វសេចក្ដី ៗ បពិត្រព្រះបម ភព ដែលផាម្ញប់លើសិរសី ព្រះនាងកណាព្រាណី បមក្សត្រីប្រសូត្របុត្រ ៗ សម្ដេច បិតុរង្គ នៃព្រះអង្គល្អបំផុត ទ្រង់ថ្វាយនាមរាជបុត្រ ដ៏បរិសុទ្ធនាមករណ៍ថា ៗ «រា-ហុល» រាជទូរស ក៏ក្រឹត្យស្រស់ដ៏ថ្ងៃថ្លា សូមទានព្រះបេស្កា មេត្តាជ្រាបតាម ពាតិមាន ៗ

(នៅមានត)

---

## សេចក្ដីរាយការណ៍អំពីការប្រជុំនៃគណៈកម្មាធិការ ទីប្រឹក្សាពុទ្ធគយា ថ្ងៃទី ១៩ មីនា ១៩៥៦ (តបប់)

ការប្រជុំនេះត្រូវធ្វើ៦ខែម្ដង, សន្និបាតលើកទី២នឹងត្រូវលើខែមិថុនា ឬកក្កដា ៗ កាលបរិច្ឆេទពិតប្រាកដនឹងកំណត់សម្រេចជាក្រោយ ហើយរដ្ឋាភិបាលពិហារនឹងបញ្ជូនសេចក្ដីព្រាងលក្ខន្តិកៈមកឲ្យសមាជិកជាតំណាងគ្រប់ប្រទេសពិនិត្យជាមុន ដើម្បីនឹងនាំយកយោបល់ទៅពិភាក្សាក្នុងពេលប្រជុំលើកទី ២ នោះ ៗ

ភិក្ខុអម្រិតានន្ទ ប្រតិភូប្រទេសនេប៉ាល់, បានថ្លែងបំណងចង់ឲ្យបានទីស្ថានពុទ្ធគយាស្ថិតនៅក្នុងកណ្ដាប់ដៃនៃអ្នកកាន់ពុទ្ធសាសនាតែម្យ៉ាង ប៉ុន្តែលោកប្រធាននិយាយឃាត់

ហើយព្រមានទីប្រជុំថា យើងបានសម្រេច, បានបំណាញច្រើនល្មមគួរសមដែរហើយ ត្រូវប្រយ័ត្នចំពោះការពិភាក្សាបែបនេះក្រែងនឹងនាំឲ្យខូចបង់ទាំងអស់ទៅវិញ " ចបើង ចង់លាភ វែងបាត់ជន់ទៅ " ។

បន្ទាប់មកមានការពិភាក្សាអំពីពិធីបុណ្យសម្ភោធពុទ្ធសករាជគំរព ២៥០០ ហើយ លោកប្រធាន បានសាកសួរអ្នកតំណាងគ្រប់ប្រទេស អំពីដំណើរដែលបូជនីយេសក៏ភាគច្រើននឹងមកកាន់ប្រទេសឥណ្ឌានៅពេលណា ,

អ្នកតំណាងគ្រប់ប្រទេសបានមូលមតិថា បូជនីយេសក៏បានភាគច្រើននឹងព្រមព្រៀងគ្នាមកកាន់ប្រទេសឥណ្ឌាក្នុងខែវិច្ឆិកាវិញ ព្រោះអាកាសធាតុប្រព្រឹត្តទៅល្អ មិនក្ដៅដូចក្នុងខែមេសា ទាំងមិនទាន់ចូលស៊ីបក្នុងរដូវរងាទៀយ ហើយដោយមានព្រឹត្តិការណ៍សំខាន់ៗដូចខាងក្រោមនេះផងគឺ :

ពីថ្ងៃទី ១០ ដល់ថ្ងៃទី ២០ វិច្ឆិកា សន្និសីទពុទ្ធិកសមាគមពិភពលោកនៅក្នុងកដ្ឋមណ្ឌុនឹងលុម្ពិនី ប្រទេសនេប៉ាល ។

កាលបរិច្ឆេទមិនទាន់កំណត់ការប្រជុំខាងព្រះពុទ្ធសាសនា នៅក្រុងដេលីប្រទេសឥណ្ឌា ។

កាលបរិច្ឆេទមិនទាន់កំណត់ពិព័ណ៌ខាងការរចនានៃព្រះពុទ្ធសាសនា នៅក្រុងដេលីប្រទេសឥណ្ឌា ។

បន្ទាប់មក របៀបវារៈ នៃការប្រជុំបានចូលដល់រឿងបែងចែកទីដីដល់រដ្ឋាភិបាលនានា ។

ក្នុងពេលនោះអ្នកចាត់ការប្រជុំ បានចែកផែនទីដីពុទ្ធគយាជូនសមាជិកទាំងអស់

ដើម្បីឲ្យបានជ្រាបជាក់អំពីទីដីដែលរដ្ឋាភិបាលពិហារទើបជាវបានមក ។

សង្កាត់ ក. (BlockA) ជាសង្កាត់នៅជិតព្រះមហាចេតិយ ហើយមានផ្ទៃដីធំទូលាយជាងគេចំនួន៥ហិចតារ៧៨អារ ។ ទីដីនេះស្ថិតនៅត្រង់ភាគឦសាន នៃព្រះមហាពោធិព្រឹក្ស ហើយអាចបែងចែកជាបីឬបួនចំណែកដ៏ធំៗបាន ។

សង្កាត់ ខ. (BlokcB) សង្កាត់ស្ថិតនៅពីខាងជើងនៃព្រះមហាពោធិព្រឹក្ស មានផ្ទៃដីតូចល្មមតែមួយចំណែកគឺចំនួន ២ ហិចតារ ។

សង្កាត់ គ. (BlockC) ទំហំ ៧ ហិចតារ៧០អារស្ថិតនៅខាងទិសនិរតីនៃព្រះមហាពោធិព្រឹក្ស ។

រដ្ឋាភិបាលពិហារនឹងអាចជាវដីដទៃបានទៀតគឺសង្កាត់លេខ ១៩២, ៣០០, ៣០១, ៣១៤, ៣១៧, ៣១៨, ៣១៩, ៣២០, ៣២១, ៣២២, ៣២៣, ៣២៤, ៣២៥, ៣២៧, ៣២៨, ៣២៩, ៣៣០, ៣៣១ ។

ក្នុងពេលនោះមានការពិភាក្សារៀបចំអំពីកិច្ចការសំខាន់ៗដែលកំពុងធ្វើ ឬដែលនឹងត្រូវធ្វើតទៅផង ។

សង្កាត់ ខ- នៅអមខាងកើតនៃភាគដីនេះ គណៈកម្មាធិការបានផ្ដង់ទុកនឹងគិតឲ្យមានផ្លូវថ្នល់មួយដែលប្រហែលជានឹងកាត់ទៅទិសខាងជើងចំពីខាងមុខសង្កាត់ដីលេខ២១០០, ២១០១, ២១០២, ២១០៣, ២១០៦, និង ២០៦៧ ។ ដែនទីផ្លូវនេះនូវមិនទាន់ប្រាកដនៅឡើយ, គណៈកម្មាធិការនឹងដាក់ជូនរដ្ឋាភិបាលពិហារសម្រេច ។

សង្កាត់ គ- មានផ្លូវមួយស្រេចហើយនៅអមខាងលិចនិងខាងជើង ភាគដីនេះជាផ្លូវអមនឹងថ្នល់ធំទៅក្រុងគយា ត្រង់កែងដែលមានផ្លូវបត់ចូលទៅពុទ្ធគយា ។

រដ្ឋាភិបាលពិហារនឹងព្រមធ្វើសន្យាជួលដី ដែលមានការកំណត់ដ៏យូរជាមួយនឹងប្រទេស ដែលត្រូវការចង់បានទីដីនៅពុទ្ធគយា ប៉ុន្តែនឹងចរចាតែរវាងរដ្ឋាភិបាលប៉ុណ្ណោះ គឺពុំព្រមចរចាជាមួយបុគ្គលឬពុទ្ធិកសមាគមទាំងឡាយឡើយ ។

អ្នកតំណាងរដ្ឋាភិបាលពិហារបានជំរាបប្រតិភូគ្រប់ប្រទេសថា ទីដីដែលប្រទេសនិមួយៗត្រូវបាននោះមិនធំប៉ុន្មានឡើយ គួរសាងសង់តែរបស់សំខាន់ៗ គឺវិហារតូចមួយសម្រាប់តែធ្វើពិធីតូចតាច, កុដិមួយខ្នងផងសាលាសំណាក់មួយខ្នង ហើយបើលើសពីនោះត្រឹមតែបណ្ណាល័យមួយខ្នងទៀតប៉ុណ្ណោះ ។

ប្រទេសភូមាសុំឲ្យកសាងទីកម្មដ្ឋានមួយ ដោយមានសួនឧទ្យានព័ន្ធព័ទ្ធជុំវិញ ដោយសុខចិត្តចេញតម្លៃកសាងចំនួន ៥០.០០០ រូពិយ ។

រដ្ឋាភិបាលពិហារនឹងធ្វើសេចក្តីរាយការណ៍ដោយសព្វគ្រប់ អំពីការជួលនិងការចេញតម្លៃឈ្នួលព្រមទាំងអំពីការអនុវត្តន៍ចំពោះទីដីដែលត្រូវបានទៅប្រទេសនីមួយៗ ហើយនឹងដាក់ឲ្យគណៈកម្មាធិការពិភាក្សាសម្រេចនៅពេលប្រជុំលើកក្រោយ ។ ឯទំហំដីនឹងរឿងផ្សេងៗ នឹងបញ្ជូនមកឲ្យសមាជិកគ្រប់ប្រទេសបានជ្រាបមុនពេលប្រជុំ ។

កាលពីពេលមុន ប្រទេសបានចរចាសុំជួលដីទំហំប្រហែល ២ ឬ ៣ហិចតា៥០ នៅភាគខាងជើងនៃសង្កាត់ "ក"

ការចរចានេះជិតដល់ទីបំផុតហើយ ប៉ុន្តែទោះបីដូច្នោះ ក៏ត្រូវតែរដ្ឋាភិបាលពិហារជាអ្នកសម្រេចក្រោយបង្អស់ដែរ ។

(តទៅទំព័រទី ៣៦)

# ពិធីបុណ្យឆ្លងឆដ្ឋសង្គាយនានិងបុណ្យពុទ្ធជយន្តិ (ត)

៤– នៅពេលចតុត្ថសន្និបាត ព្រះរាជរដ្ឋាភិបាលប្រទេសយើងបានចាត់គណៈប្រតិភូព្រះសង្ឃខ្មែរដែលមានព្រះគ្រូវិសុទ្ធិមុនី ជួន-ណាត ជាប្រធានឲ្យទៅរួមប្រជុំក្នុងទីនោះៗ

រាល់តែសន្និបាត គណៈប្រតិភូខាងព្រះពុទ្ធសាសនាពីគ្រប់ប្រទេសបានទៅរួមប្រជុំនោះៗ គណៈប្រតិភូខ្មែរយើងក៏បានទៅរាល់លើកដែរ តែថែមទៀតនៅពេលបញ្ចមសន្និបាតនេះ គណៈប្រតិភូនៃប្រទេសជាមិត្តពុទ្ធសាសនិកទាំងអស់បានទៅជួបជុំមូលត្រកូលគ្នា បាត់មុខតែគណៈប្រតិភូព្រះសង្ឃខ្មែរអត់ឮអ៊ីម៉េះ តែគណៈប្រតិភូខ្មែរហ្ន៎ ! ៗ កាលបើនឹកដល់រឿងនេះម្ដងៗ ខ្ញុំមានសេចក្ដីស្ដាយក្រៃលែងស្ដាយ ដោយយល់ឃើញថា បញ្ចមសន្និបាតនោះជាទីបំផុត ជាពេលធ្លងបុណ្យឆដ្ឋសង្គាយនាយ៉ាងឧឡារិកអធម ហើយនឹងជាពេលធ្វើបុណ្យពុទ្ធជយន្តិគឺបុណ្យពាក់កណ្ដាលសាសនានៃព្រះសម្ពុទ្ធបរមគ្រូ ឬជាបុណ្យ២៥០០ព្រះវស្សានៃព្រះពុទ្ធសាសនាផងៗ នៅពេលបុណ្យទាំងពីរនោះពុទ្ធមាមកជនប្រទេសភូមាទាំងរដ្ឋាភិបាលទាំងប្រជាជនបានពួតកំលាំងគ្នាធ្វើយ៉ាងពេញទំហឹងៗ

សង្គាយនាលើកទី ៦ គឺឆដ្ឋសង្គាយនានោះ អាចចាត់បានថាជាសង្គាយនាយ៉ាងប្រសើរមួយដែលច្រើនសម័យមកហើយ ការធ្វើសង្គាយនាពុំដែលបានជួបជុំគ្នាច្រើនប្រទេសដូចម្ដងនេះទេ ៗ លើកនេះមហាប្រទេសខាងពុទ្ធសាសនាទាំង៥គឺ ខ្មែរ, ភូមា, លង្កា, សៀមនិងលាវបានមករួមគ្នាធ្វើ ឯប្រទេសឯទៀតជាច្រើនក៏បានមករួមជាមួយដែរ តែជាប្រទេសដែលមានពុទ្ធសាសនិកជនតិចតួចខ្លះក៏នៅជាមហាយាន (អាចារិយវាទ) ដូចជា៖ នេប៉ាល, ប៉ាគីស្ថានខាងកើត, បេង្គាល់, អាសាំ, វៀតណាមខាងត្បូង, ជប៉ុន, ចិនប្រជាមានិត (ល) ... ៗ

# កាលបរិច្ឆេទនៃសន្និបាតទាំង៥លើក

## បឋមសន្និបាត

១– បឋមសន្និបាតឈ្មោះថាមរម្មសន្និបាត ឬ សន្និបាតរបស់ភូមា មានស្យាដោ អភិធជមហារដ្ឋគុរុ ញោង-យ៉ាំង ជាប្រធានសង្ឃ ។ ពិធីបើកបុណ្យឆដ្ឋសង្គាយនាបាន បើកសម័យពីថ្ងៃ ១៥ កើតខែពិសាខ ព.ស.២៤៩៨ (១៧ ឧសភា ១៩៥៤) អស់រយៈវេលា៣ថ្ងៃ; ទើបព្រះសង្ឃចាប់ស្វាធ្យាយពីថ្ងៃ៤រោចខែ-ឆ្នាំដដែល (២១ ឧសភា-៥៤) រហូតដល់ថ្ងៃ៧កើតខែអាសាឍ្ហ ឆ្នាំដដែល (៧កក្កដា៥៤) អស់កាល៤៦ថ្ងៃ ។

## មរម្មសន្និបាត

២– ទុតិយសន្និបាតក៏ឈ្មោះថាមរម្មសន្និបាតដែរ ព្រោះមានព្រះមហាថេរ អភិធជមហារដ្ឋគុរុ ញោង-យ៉ាំង ដដែលជាប្រធាននៃសង្ឃ ។ សន្និបាតនេះបានចប់ស្រេចក្នុងរយៈកាល៧៥ថ្ងៃ គឺ ពីថ្ងៃ៥រោចខែកត្តិក ព.ស.២៤៩៨ (១៥វិច្ឆិកាគ.ស.១៩៥៤) ដល់ថ្ងៃ៦កើតខែមាឃ ព.ស.២៤៩៨ (២៩មករា១៩៥៥) ។ នៅពេលបើកសម័យប្រជុំលើកទីពីរ , សម្តេចព្រះឧបយុវរាជកាលដែលទ្រង់គង់នៅក្នុងរាជសម្បត្តិនៅឡើយ បានស្តេចយាងទៅជាភ្ញៀវមួយព្រះអង្គយ៉ាងឆើតក្នុងចំណោមភ្ញៀវកិត្តិយសរវាងរដ្ឋទាំងនោះ ហើយព្រះអង្គបានបើកសម័យប្រជុំនោះឯង ។

## កម្ពុជលាវសន្និបាត

៣– តតិយសន្និបាត ឈ្មោះថា កម្ពុជលាវសន្និបាត គឺជាសន្និបាតរបស់កម្ពុជានិងលាវព្រោះចែកជាពីចំណែកគឺ:

ក–) ចំណែកទីមួយ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិ-

កាយជាប្រធាននៃព្រះសង្ឃជាសង្គីតិការកៈបានឈ្មោះថា កម្ពុជសន្និបាត ។

១–) បំណែកទីពីរ សម្ដេចព្រះសង្ឃនាយកគណៈមហានិកាយនៃប្រទេសលាវ ជាប្រធាននៃសង្ឃបានឈ្មោះថា លាវសន្និបាត ។ ដូច្នេះ សន្និបាតនោះឈ្មោះថា កម្ពុជលាវសន្និបាត ។ សន្និបាតទី៣នោះឯងធ្វើអស់រយៈវេលា ៣០ថ្ងៃ គឺចាប់តាំងពីថ្ងៃ ៧ កើតខែពិសាខ ព.ស.២៤៩៨ (២៨មេសា គ.ស.១៩៥៥) ដល់ថ្ងៃ ៧ កើតខែជេស្ឋ ព.ស.២៤៩៩ (២៨ឧសភា១៩៥៥) ។

ឯភ្ញៀវផ្សេងដែលទៅជាកិត្តិយសក្នុងពេលបើកសម័យប្រជុំនោះគឺ ព្រះអង្គម្ចាស់ សាវ៉ាង វឌ្ឍនា ជាព្រះរាជទាយាទប្រទេសលាវព្រមទាំងព្រះអង្គម្ចាស់ស្រី នឹងធីតារបស់ទ្រង់, លោកគន់-អភ័យនាយករដ្ឋមន្ត្រីប្រទេសលាវនឹងក្រុមអមព្រះអង្គ, ឯ.ឧ. ឡេង-ង៉ែតនាយករដ្ឋមន្ត្រីប្រទេសកម្ពុជា, លោក ស៊ូរ៉ប់-ផែតសិ៍ ប្រធានបេសកកម្មផ្នែកពុទ្ធសាសនានៃប្រទេសចិនប្រជាមានិត ។

## ស្យាមសន្និបាត

៤– សន្និបាតរបស់ថៃគឺ សន្និបាតលើកទី៤, ធ្វើអស់រយៈកាល៦៣ថ្ងៃ គឺពីថ្ងៃ ២កើតខែមិគសិរ ព.ស. ២៤៩៩ (១៦ធ្នូ គ.ស. ១៩៥៥) ដល់ថ្ងៃ ៥ កើតខែមាឃ ព.ស. ២៤៩៩ (១៦កុម្ភ គ.ស. ១៩៥៦) ។

នៅពេលនោះព្រះមហាបាសាណគុហាសម្រាប់ឆដ្ឋសង្គាយនាមានការប្រដាប់តាក់តែងដោយក្បាច់ក្បូរវិចិត្រដោយភ្ញីផ្កាផ្សេងៗ បែបវិចិត្រកម្មរបស់ថៃ មានសម្រស់ត្រចះដ៏ត្រចង់គួរជាទីរីករាយពន់ពេក ។

(នៅមានត)

# បុរាណនិវេសន៍ (គ)

អតីតកាលទ្រង់ព្រះនាម ព្រះស្រីសុគន្ធបទដែលទ្រង់សោយរាជ្យនៅក្រុងចាស់នេះ បរិបូណ៌ដោយស្រីស្នំក្រមការប្រកបដោយសេចក្ដីសុខក្នុងសិរីរាជសម្បត្តិ ពេលនោះ ជាអកុសលរបស់ទ្រង់យ៉ាងធំ មានគ្រោះបណ្ដាលឲ្យនាយកនម្នាក់ជាអ្នកក្បត់ទ្រង់ធ្វើគត់ព្រះអង្គទៅ ៗ មានសម្ដេចមួយព្រះអង្គព្រះនាមព្រះមហិន្ទរាជា ទ្រង់ឡើងសោយរាជសម្បត្តិតមក, គ្រានោះមានមនុស្សម្នាក់ធ្វើជាគ្រូពេទ្យពូកែណាស់ ឈ្មោះព្រះរៀមជើងព្រៃ ពួកអ្នកស្រុកចុះចូលរាប់អានបានគ្នាច្រើន ក៏បះបោរដណ្ដើមយករាជសម្បត្តិពីស្ដេចមហិន្ទរាជាបាន, ក៏ចូលទៅនៅក្នុងរាជវាំងនោះ ទើបមានសាសន៍ជាតិពកិទុយ-តេស គេឡោមព័ទ្ធចាប់ព្រះរៀមជើងព្រៃយកទៅសម្លាប់ចោលទៅ ក៏បាននាំគ្នាទៅអញ្ជើញព្រះមហិន្ទរាជាឲ្យទ្រង់ឡើងសោយរាជសម្បត្តិ, ទ្រង់ក៏ទីវង្គតនាពាក់កណ្ដាលផ្លូវនោះ ដោយព្រះរោគមួលបុះឈាម ៗល។ ក្រុងនេះក៏ដល់នូវសេចក្ដីអន្តរាយរលាយបន្តិចម្ដង ៗ ដរាបទាល់តែក្លាយទៅជាព្រៃស្បាតដុះពាសពេញសុទ្ធតែឈើរហូតរៀងមកដល់សព្វថ្ងៃនេះ បាត់ជ្រុងជ្រោយទីនោះអស់រលីងទៅ ៗ

ឯបុរាណវត្ថុ គឺប្រាង្គចេតិយធំ ៗ ដែលគេបានកសាងប្រតិស្ឋានទុកជាបូជនីយដ្ឋានជាថាវរវត្ថុ ដែលជានិមិត្តរូបឲ្យឃើញប្រចក្សជាក់ស្ដែងភស្តុតាងប្រាកដនៅក្នុងវត្តព្រះរាជនិវេសន៍ស្ថានសព្វថ្ងៃនេះ មានដល់ ៦ គឺ នៅទីខាងមុខវិហារ៤ នៅទីវាលខាងក្រោយវិហារ ២ ប្រាង្គចេតិយខ្លះធ្វើអំពីឥដ្ឋធំ ៗ ខ្លះធ្វើអំពីថ្មបាយក្រៀម មានទទឹងនឹងបណ្ដោយ ៤ ជ្រុងស្មើ, ខ្លះ ១៥ ម៉ែត្រ ខ្លះ ១២ ម៉ែត្រ ខ្លះ ១០ ម៉ែត្រ ហើយមានកំពូលត្រដួចស្រួចទៅលើអាកាសខ្ពស់ប្រហែលជា៧-៨ម៉ែត្រខ្លះ ប្រាង្គចេតិយនេះហើយដែល

ជាស្នាដៃនៃហត្ថកម្មរបស់បុរាណកាលកសាងប្រមាណជាង ៩០០ ឆ្នាំហើយសម្រាប់ទុកជាបូជនីយដ្ឋានតរៀងមកជាប់ស្ថិតថេរចិរកាលដល់ឥឡូវនេះ ។

ប្រាង្គចេតិយធំទាំងនេះ ប្រហែលជាគេបញ្ចុះព្រះអដ្ឋិធាតុព្រះមហាក្សត្រ ព្រះអង្គម្ចាស់ ឬព្រះអរហន្តធាតុ តាមដំណឹងថា: ប្រាង្គចេតិយធំនៅទិសអគ្នេយ៍ចម្ងាយប្រហែលជា ៣០ ម៉ែត្រពីទីជ្រុងឃឿននៃវិហារធំនេះទៅ គេប្រាប់ថាបានបញ្ចុះព្រះអដ្ឋិធាតុ ព្រះអរហន្ត ១ អង្គព្រះនាមព្រះមហាអានន្ទហើយប្រាប់ថា ប្រាង្គធំនេះឯង គេបាញ់កាំភ្លើងមិនចេញទេ ពិតដូច្នោះមែន! កាលដែលលោកសេហ្វប៉ុស្តិ៍ វិហារសួរ អញ្ជើញមកបុណ្យបញ្ចុះអដ្ឋិធាតុព្រះសពព្រះនាម (ម៉ា-សៀង) នៅថ្ងៃ ១៣ កើត ខែផល្គុណឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ ត្រូវនឹង ២៣ ខែមិនា (Mars) ១៩៤៨ ក្នុងចេតិយសាងថ្មីនេះ លោកនឹងប៉ូលិសឃុំ បានលើកកាំភ្លើងទាំងពីរនាក់ដាក់សំដៅបំទៅត្រង់ប្រាង្គចេតិយធំនៅទិសអគ្នេយ៍នោះ ហើយយឹតកៃឮសូរប្រិបបាញ់ទៅ តែមិនចេញសូរសំឡេងឮកឹងទៅ បាញ់យ៉ាងនេះដល់ទៅពីរលើកមិនចេញសោះ ទើបលោកលើកកាំភ្លើងដម្រង់ចំទៅដើមសម្រោងទិសខាងកើតវិញ កាំភ្លើងក៏ចេញសំឡេងឮសូរពិតគួរឲ្យអស្ចារ្យ មនុស្សប្រុសស្រីក៏បានឃើញប្រាកដជាក់ស្ដែងដោយភ្នែកគ្រប់គ្នា ឯខ្ញុំក៏ភ្ញកនឹកដល់ពាក្យមនុស្សម្នាក់ឈ្មោះ (អ៊ុង-ជា) គាត់ជាអាចារ្យបង្រៀនធម៌ប៉ែកខាងព្រះកម្មដ្ឋានដែលបានបាត់បង់ជីវិតទៅហើយ គាត់បានប្រាប់ថាប្រាង្គចេតិយធំនេះបាញ់មិនចេញទេ ខ្ញុំក៏កត់សំគាល់ទុកមកតែម្នាក់ឯង គ្មានអ្នកណាមួយសួរដឹងដល់ការណ៍នេះទេ លុះប្រទះឃើញលោកសេហ្វប៉ុស្តិ៍បាញ់មិនចេញដូច្នោះ ក៏នឹកស្ញើបរន្ធត់ចិត្តតែម្នាក់ឯងក្នុងទីប្រជុំមនុស្ស កំពុងបញ្ចុះអដ្ឋិធាតុព្រះសពព្រះនាម

(ម៉ា-សៀង) នោះ ៗ

រឿងមួយទៀតថា លោកអាចារ្យ (គង់-គឹម) ជាអតីតាចារ្យសម្រាប់វត្តស៊ីធរ ដែលអនិច្ចធម្មទៅហើយ កាលដែលគាត់បួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា បានសិក្សារៀនធម៌សមណៈព្រះកម្មដ្ឋាន បែកខាងផ្លូវធ្មេង ដែលពាក្យអ្នកស្រុកហៅថា មេក-ថ្នាយ គាត់បាននិយាយប្រាប់ខ្ញុំជាយូរឆ្នាំហើយថា: ប្រាង្គចេតិយធំនៅទិសអាគ្នេយ៍នោះ មានព្រាយសម្បុរពណ៌ខៀវនៅអាស្រ័យតូកែណាស់ទាក់យកមិនបានទេ ខ្ញុំសួរគាត់ថា មុិចក៏ដឹងថាមានព្រាយនៅ? គាត់ប្រាប់ថា: កាលណោះមានភិក្ខុ ៣ រូបចង់ដឹងវិជ្ជាធម៌របស់គាត់ គេបានពិសោធគាត់ថាជាអ្នកចេះតូកែខាងផ្លូវធម៌ព្រះកម្មដ្ឋានបួលក្នុងឈានលោកិយមែន ឬ? គាត់ក៏ធោតតាមគេ ៗ ក៏ឲ្យគាត់ទៅអង្គុយធម៌នៅក្នុងព្រៃត្រង់ទីចន្លោះនៃវិហារតូចនិងវិហារធំ នៅក្បែរកន្ទ្រុបព្រៃមួយដុំមានដើមសារម៉ាវដុះព័ទ្ធជុំវិញ ហើយគាត់អុចធូប ៣ សរសៃអង្គុយពែនជើងសម្រឹងចិត្តពឹងនឹកដល់ធម៌ ខ្ញុំសួរគាត់ថា៖ បុះសូត្រការនាធម៌អ្វី? គាត់ថាទេ! មិនចាំបាច់សូត្រការនាធម៌ទេ! គ្រាន់តែសម្រឹងចិត្តនឹកក៏ដល់ភ្លាម គាត់បានឲ្យភិក្ខុ ៣ រូបនោះថយចេញទៅអង្គុយឲ្យឆ្ងាយពីគាត់លបតួនចាំមើលគាត់ចុះ គាត់ក៏តាំងចិត្តប្រុងចុះបំពោះធម៌ភ្លាម ស្រាប់តែព្រាយចេញភ្លូតស្រែកធ្ងូក ៗ ហោះចេញពីដើមត្របែកព្រៃដើមធំដែលដុះនៅក្បែរហៀនវិហារតូច ហោះមកធ្វើប្រទក្សិណដែនសីមារបស់គាត់ក្រឡឹង ៣ ជុំ ទើបធ្លាក់ចុះទៅក្នុងសីមាគាត់ ៗ ក៏យកទុកទៅ (គឺវត្ថុយួច), បន្តិចមកទៀត មានព្រាយនៅប្រាង្គចេតិយធំទិសឦសាននៃវិហារ ព្រាយនៅដើមពោធិធំខាងមុខវិហារក៏បានហោះមកធ្វើប្រទក្សិណ ៣ ជុំ ហើយធ្លាក់ចុះក្នុងសីមារបស់គាត់ដែរ, ៗ (នៅមានត)

# ធនញ្ជយបណ្ឌិត (គ)

## ១– មលតរគាថា

អថេសទិវសំ ថ្ងៃមួយក្នុងកាលជាខាងក្រោយមក ព្រះរាជាទ្រង់ក្នុកព្រះទ័យចង់ចេញទៅប្រពាធព្រៃដើម្បីបរបាញ់សត្វក្រសាលព្រះទ័យ ទ្រង់លើករេហ៍ពលសកលយោធាចតុរង្គសេនាចេញទៅបានលោមព័ទ្ធព្រៃកំប៉ុត១ដែលមានមេម្រឹកសម្ងំនៅ ដើម្បីកុំឲ្យសត្វម្រឹកនោះរត់រួច ស្រាប់តែមេម្រឹកវាភ័យណាស់ឃើញចន្លោះទូលាយចំពោះព្រះភ័ក្ត្រព្រះរាជា វាក៏ពោលរួចអំពីនោះទៅ ព្រះរាជាក៏ទ្រង់ឡើងគង់លើខ្នងអស្សតរ៍បរបំផាយយ៉ាងលឿនឥតមានទាហានណាតាមទាន់ឡើយ មេម្រឹកវារត់ចូលព្រៃជ្រៅបាត់ទៅ ស្ដេចក៏ចេះតែបំផាយសេះតាមឆ្ងាយទៅ ៗ ដាច់សង្វែងស្នូលគ្មានក្រយ៉ាអស់កម្លាំងខ្លាំងពន់ពេក ទ្រង់ធ្មៀងព្រះនេត្រទតទៅឃើញដើមជ្រៃមួយដើមមានម្លប់ត្រឈឹងត្រឈៃសាខាជាទីត្រជាក់ត្រជុំសុខដុំក្រៃលែង ក៏ទ្រង់ចុះពីលើខ្នងអស្សតរ៍យាងចូលទៅសម្រាកព្រះកាយពលនៅក្រោមម្លប់ជ្រៃនោះ ស្មានថាបានសុខស្រួលហើយ ៗ ក៏ប្រារព្វទឹងផ្ទំសម្រាក ៗ ស្រាប់តែមានយក្សជាម្ចាស់ដើមជ្រៃនោះដែលបានអំណាចអំពីព្រះបាទវេស្សវណ្ណ (ជាស្ដេចខ្មោច ប្រគល់ជ្រៃនោះឲ្យចំពោះតែអ្នកណាដែលចូលមកជ្រកម្លប់ជ្រៃ យក្សតែងតែចាប់សម្លាប់ស៊ីជាចំណីយូរឆ្នាំមកហើយ លើកលែងតែនរណាចេះមលតរធម៌ចេញ ៗ ពេលនោះយក្សចាប់ព្រះរាជាដាប់ទឹងញេញធ្មេញដាក់ហាក់ដូចជាទឹងចង់ទំពាស៊ីព្រះអង្គទាំងស្រស់ យក្សក៏សួរថា អ្នកឯងមកពីណា? ទៅណា? មកជ្រកម្លប់ជ្រៃមិនសុំម្ចាស់គេសិន? ឈ្មោះអ្វី? អ្នកឯងចេះមលតរធម៌ឬទេ? ព្រះរាជាទ្រង់ភ័យញ័រជាខ្លាំងរកទីបំផុតគ្មាន ស្មានថាមុខជាយក្សសម្លាប់ព្រះអង្គហើយ ក៏ទ្រង់ឆ្លើយតបទៅយក្សវិញថា ម្នាលនន្ទិយក្សដ៏ចំរើន យើងជាស្ដេចព្រះនាម ធនញ្ជយកោរព្យ

រាជ នៅនគរឥន្ទបត្តបុរី យើងមកពីប្រពាតព្រៃ អស់កម្លាំងខ្លាំងពេកចូលមកសម្រាកក្រោមម្លប់របស់អ្នកឯង មិនដឹងថាអ្នកជាម្ចាស់ទេ ព្រោះយើងមើលអ្នកមិនឃើញសោះ លុះតែអ្នកឯងនិមិត្តឲ្យឃើញយ៉ាងនេះទើបដឹងបាន ឯមលគរៈធម៌សោតយើងមិនដែលបេះទេ ។ ទើបយក្សឆ្លើយថា : «បើដូច្នោះខ្ញុំត្រូវបរិភោគព្រះអង្គជាអាហារឥឡូវនេះហើយ» ។ ព្រះរាជាទ្រង់អង្វរយក្សថា: យើងជាស្ដេចសុំឱកាសដើម្បីទៅរកអ្នកប្រាជ្ញដែលបេះមលគរៈធម៌បញ្ជូនមកឲ្យអ្នក បើទៅរក៧ថ្ងៃហើយមិនបានអ្នកប្រាជ្ញទេ យើងនឹងមកជូនឯងឲ្យអ្នកបរិភោគយើងជាអាហារប៉ុះបានឬទេ ?

យក្សឆ្លើយថា ក្រែងស្ដេចយាងដោះដៃពីយក្សរួចហើយលោក្រអឹតមិនត្រឡប់មកឲ្យស្លាប់វិញទេដឹង ?

មានព្រះបន្ទូលតបនឹងយក្សថា ៖ យើងជាស្ដេចតែងប្រកបអង្គ៥ប្រការមិនដែលដាច់គឺ:

១– សុភេច អង់អាចក្លាហាន ។

២– មហិទ្ធិភោប មានមហិទ្ធិឫទ្ធិខ្លាំង ។

៣– បរមុនោ ប អាចញុំញីនូវសត្រូវទាំងពួងបាន ។

៤– វចនសន្ទហក្ខគោ ប ប្រាកដជាអ្នកមានសំដីគប្បីជឿ ។

៥– វចនមធុភោ ប តែងពោលពាក្យពីរោះផ្អែមប្រកបដោយច្បាប់ជាធម្មតា ។ យើងជាស្ដេចតែងប្រកបដោយអង្គ៥ប្រការនេះមិនដែលដាច់ឡើយ តែងកាន់សច្ចៈជាប់ជានិច្ច ដូចស្ត្រីសម្រាលបុត្រចេញពីផ្ទៃហើយ មិនដែលបញ្ចូលបុត្រទៅក្នុងផ្ទៃវិញឡើយ យើងជាស្ដេចពោលពាក្យណាហើយ ពាក្យនោះមិនត្រឡប់ចូលទៅក្នុងមាត់វិញបានទេ យើងមុខជាវិលត្រឡប់មកពុំខានឡើយត្រូវអ្នកឯងជឿចុះ ។ យក្ស

បានស្តាប់ពាក្យប្តេជ្ញានៃព្រះរាជាហើយ ក៏ទទួលយល់ព្រមលែងស្តេចឲ្យយាងទៅរកអ្នកប្រាជ្ញ៧ថ្ងៃ ប៉ុន្តែផ្តាំថា: ព្រះអង្គយាងទៅស្វែងរកអ្នកបេះមលគរធមិបាន សូមបញ្ជូនតែអ្នកនោះមកឲ្យខ្ញុំបានហើយ មិនបាច់ព្រះអង្គយាងមកឡើយបើរកអ្នកប្រាជ្ញមិនបានទេ ត្រូវយាងមកតែមួយព្រះអង្គឯងចុះខ្ញុំនឹងទំពាស៊ីតែព្រះអង្គ១ប៉ុណ្ណោះ បើដល់៧ថ្ងៃហើយបាត់សូន្យមិនឃើញអ្នកប្រាជ្ញ មិនឃើញព្រះអង្គយាងមកទេ ខ្ញុំនឹងលើកពលយក្សទៅចាប់ព្រះអង្គនឹងរាជបរិស័ទ្ធទាំងនគរ តែមួយព្រឹបរិភោគឲ្យអស់មិនឲ្យមានសល់ដល់ម្នាក់ឡើយ ដូច្នេះសូមស្តេចយាងទៅចុះ ។

ព្រះរាជាបានទទួលពាក្យប្តេជ្ញាយ៉ាងនេះហើយ ទ្រង់យាងត្រឡប់ចូលមកកាន់នគរវិញ ហើយបានប្រជុំនាហ្មឺនមុខមន្ត្រីនិងអ្នកប្រាជ្ញ-ព្រាហ្មព្រឹទ្ធបណ្ឌិតហោរា ចរចារប្រាប់ពីសេចក្តីទុក្ខភ័យធំដែលបានប្តេជ្ញានឹងយក្សបានតែ៧ថ្ងៃប៉ុណ្ណោះបើរកអ្នកប្រាជ្ញដែលបេះមលគរធមិបាន យើងនឹងបានរួចពីសេចក្តីស្លាប់ទាំងអស់គ្នាហើយ, ទ្រង់ប្រឹក្សសួររកអ្នកប្រាជ្ញដែលបេះមលគរធមិតាំងតែពីថ្ងៃទី១រហូតដល់ថ្ងៃទី៦ គ្មាននរណាមួយដឹងឮថា មលគរធមិយ៉ាងម៉េច ៗ សោះសូម្បីតែអ្នកប្រាជ្ញចាស់ ៗ សម្រាប់នគរក៏សុទ្ធតែមិនបេះទាំងអស់គ្នា ព្រះរាជាទ្រង់ព្រះចិន្តាថា ឱ ! ជីវិតរបស់អញនឹងស្លាប់សូន្យក្នុងថ្ងៃស្អែកនេះពុំខានឡើយ ព្រោះស្វែងរកអ្នកប្រាជ្ញបេះមលគរធមិផុតអស់ក្នុងថ្ងៃនេះហើយ អស់បានហើយ ! ទើបព្រះអង្គទ្រង់ផ្តែផ្តាំអស់សេនាបតី កុង្សសេវកាមាត្យទាំងឡាយថាម្នាលអ្នកទាំងឡាយ ស្អែកនេះយើងសូមលាអ្នកពល់គ្នាទៅតែម្នាក់ឯងឲ្យយក្សបរិភោគជាអាហារនឹងស្លាប់បង់ជីវ៉ាចោលអ្នកពល់គ្នា ក្នុងគ្រាថ្ងៃស្អែកនេះហើយ ចូរអ្នកទាំងអស់គ្នាថែរក្សាគ្នាក្នុងនគរឲ្យបានសុខសប្បាយពល់គ្នាចុះ សូមលាហើយ ៗ (នៅមានត)

# ជ័យប្រាជ្ញ (ត)

ពួកអាមាត្យ ណ្ហើយ! អាជ័យ! កុំប្រាប់អាឯងឡូកឡឺយឲ្យយើងធ្វើអី ចាំមើលពេលក្រោយ បើព្រះមហាក្សត្រិត្រាស់ហៅឲ្យអាឯងមកទៀត នោះយើងប្រាកដជាសុំចាញ់អាឯងតែម្តង ។

កុមារជ័យ អស់លោកសុំចាញ់នេះ តើសុំចាញ់ទទេ ឬសុំចាញ់មានស៊ីសង ។

ពួកអាមាត្យ យើងសុំចាញ់ទទេ ។

កុមារជ័យ ពាក្យនេះពិតមែនឬ? ។

ពួកអាមាត្យ ពិតមែន ។

កុមារជ័យ ចុះបើត្រឡប់ជាពាក្យនេះមិនពិតទៅវិញ តើមាននរណាធ្វើកសិណសាក្សី ។

ពួកអាមាត្យ យើងទាំងអស់គ្នាធ្វើជាកសិណសាក្សី ។

កុមារជ័យ គ្មាននរណាប្រព្រឹត្តលើសខ្លួនឯង ហើយយកខ្លួនឯងធ្វើសាក្សីទេ ។

ពួកអាមាត្យ ណ្ហើយ! អាឯង! ទៅផ្ទះទៅ កុំនៅនិយាយតាតង់អារង់ធ្វើអីទៀត ។

កុមារជ័យ អ្នកណាសួរខ្ញុំមុន ឥឡូវខ្ញុំនិយាយហើយម្តេចក៏បណ្តេញខ្ញុំឲ្យទៅផ្ទះ មិនព្រមឲ្យនិយាយ នេះហៅកិរិយាប្រព្រឹត្តរំលោភព្រោះអាងតែខ្លួនធំ មើលងាយគេតូច បង្គ្របទាំងអំណាច ។

ពួកអាមាត្យ យើះ! អានេះរឹងមាត់ណាស់តើ ឲ្យវាទៅផ្ទះក៏វាមិនព្រមទៅ បន្តិចដល់ថ្នាក់អញអត់មិនបាន ។

កុមារជ័យ លោតទន្ទ្រាំជើងស្រែកយំខ្លាំងៗ ថាអញមិនព្រមទៅផ្ទះទេ ថាអញសុខចិត្តនៅឲ្យស្លាប់ក្នុងទីនេះ ព្រោះតែគេនិយាយបម្រុងនឹងកុហកអញ ។

ពួកអាមាត្យ នែ! អាជ័យ! ប្រយ័ត្នអញទៅក្រាបបង្គំទូលព្រះមហាក្សត្រ ។ នឹងយកទោសអាឯងមិនខាន ។

កុមារជ័យ បើព្រះមហាក្សត្រយកទោសដល់ជីវិតខ្ញុំ តែតែអរជាងរស់នៅចាញ់គេយ៉ាងនេះ ។

អាមាត្យចូលទៅក្រាបបង្គំទូលព្រះមហាក្សត្រ ។ ទ្រង់ត្រាស់ឲ្យហៅកុមារជ័យចូលទៅដល់ ហើយទ្រង់មានព្រះបន្ទូលសួរថា នែ! អាជ័យ! ហេតុអ្វីក៏អាឯងយំមិនព្រមទៅផ្ទះ ។

កុមារជ័យ សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំចេញទៅផ្ទះហើយ តែពួកសេវកាមាត្យសាកសួរទូលព្រះបង្គំ ។ ក៏បាននិយាយរៀបរាប់ហូរហែតាំងតែអំពីខ្លួនទូលព្រះបង្គំដែលគ្រិចមិនស្អាត មិនគួរនឹងបានចូលមកក្នុងព្រះបរមរាជវាំងសោះ បើតាមទំនាយរបស់ពួកអស់លោកទាំងនោះពីថ្ងៃមុន ។ តែមិនដូច្នោះត្រឡប់ជាព្រះអង្គទ្រង់ព្រះមេត្តាប្រោសហៅទូលព្រះបង្គំចូលមកដោយព្រះរាជហឫទ័យដ៏បរិសុទ្ធទៅវិញ ។

ដោយហេតុនេះពួកអស់លោកទាំងនោះ ក៏ស្រដីមកកាន់ទូលព្រះបង្គំថា ចាំមើលពេលក្រោយ បើព្រះមហាក្សត្រត្រាស់ហៅអាឯងឲ្យចូលមកទៀត នោះយើងប្រាកដជាសុំចាប់អាឯងតែម្ដង ។ ទូលព្រះបង្គំបានសួរត្រឡប់ទៅវិញថា “ សុំចាប់ទេ ឬសុំចាប់មានស៊ីសង ” ពួកអស់លោកទាំងនោះក៏ឆ្លើយប្រាប់មកទូលព្រះបង្គំថា “ សុំចាប់ទេ ” ។ ទូលព្រះបង្គំបានបញ្ជាក់តទៅទៀតថា បើសុំចាប់ តើមាននរណា

ជាសាក្សី ជួយដឹងឮចំពោះរឿងនេះផង ។ ពួកអស់លោកទាំងនោះឆ្លើយថា សាក្សីជួយដឹងឮរឿងទាំងនេះលើខ្លួនលោកទាំងអស់គ្នា ។ ទូលព្រះបង្គំថាមិនដែលមាននរណាប្រព្រឹត្តអំពើអ្វីមួយដោយខ្លួនឯង ហើយយកខ្លួនឯងជាសាក្សីបានទេ ។ អាស្រ័យរឿងពួកអស់លោកបានបណ្ដេញទូលព្រះបង្គំឲ្យទៅផ្ទះ ទូលព្រះបង្គំមិនសុខចិត្តទៅ ព្រោះយល់ឃើញថាអស់លោកទាំងនោះ និយាយប្រុងនឹងកុហកទូលព្រះបង្គំ ដោយហេតុមិនព្រមយកសាក្សីពេញច្បាប់ មកជាទីតាំងចំពោះការសុំចាញ់ទេនោះ ។

សូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រទ្រង់ត្រាស់សួរពួកអាមាត្យទាំងនោះវិញថា នែ! នាយទាំងឡាយ ពាក្យដែលអាជ័យបានរៀបរាប់មកនេះពិតមែនឬទេ ? ។

ពួកអាមាត្យ – សូមទ្រង់ព្រះមេត្តាប្រោសពិតមែន ។

ព្រះមហាក្សត្រ – បើដូច្នោះអញនឹងធ្វើសាក្សីឲ្យអ្នកពល់គ្នាបានឬទេ ? ។

ពួកអាមាត្យ – សូមទ្រង់ព្រះមេត្តាប្រោស គ្រាន់តែទ្រង់ជំនុំជំរះរឿងនេះឲ្យនោះ ទូលព្រះបង្គំមានសេចក្ដីត្រេកអរណាស់ទៅហើយ ដោយទូលព្រះបង្គំរំពឹងតែសប្បុរធម៌ដែលមាននៅក្នុងព្រះរាជហឫទ័យ របស់ព្រះអង្គទេ ។

ព្រះមហាក្សត្រ – ចុះចំណែកខាងអាជ័យ ឯងសុខចិត្តនឹងគេដែរឬទេ ? ។

កុមារជ័យ – សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំសុខចិត្តចំពោះតែសេចក្ដីពិតដែលអស់លោកទាំងនោះព្រមទទួលយកការសុំចាញ់ទេ ដូចសំដីដើម បើប្រែថាមិនទទួលទៅវិញ នោះទូលព្រះបង្គំមិនសុខចិត្តផងទេ ។

(នៅមានត)

(សេចក្ដីរាយការណ៍ គ)

លោក ស.ក. មូគ័រជី បានថ្លែងប្រាប់ទីប្រជុំថា ទីដីដែលត្រូវចែកឲ្យប្រទេសនិមួយ ៗ មានទំហំតែត្រឹមរវាង១ហិចតា២១អារប៉ុណ្ណោះពុំបានធំលើសពីនោះឡើយ ។ ឯកឧត្ដម ព្រះពហិទ្ធនុករ ប្រតិភូនៃប្រទេសថៃយ៍បានសុំឲ្យបញ្ជាក់សម្រេចអំពីទំហំដីដែលប្រទេសថៃត្រូវបានតាមបទបរចាអំពីខាងដើម ប៉ុន្ដែអ្នកតំណាងប្រទេសដទៃ ៗ បានជជែកតវ៉ាថា ត្រូវតែបានទីដីប៉ុន ៗ គ្នា, ដោយហេតុនេះទើបអ្នកតំណាងរដ្ឋាភិបាលពិហារពុំព្រមបញ្ជាក់ឲ្យហើយនឹងទុកការសម្រេចនេះឲ្យជាការៈនៃរដ្ឋាភិបាល (ពិហារ )។

រដ្ឋាភិបាលដែលនឹងអាចបានចំណែកដីនៅពុទ្ធគយាគឺ ភូមា, កម្ពុជា, លង្កា, ចិន, ជប៉ុន, លាវនឹងថៃ ។ ប្រទេសភូមា, ចិន, នឹង ទីបេត៍មានទីដីរបស់ខ្លួននៅពុទ្ធគយាពីដើមមកហើយ, គ្រាន់តែរាសពង្រីកឲ្យធំទូលាយជាងមុនបន្តិចក៏ជាការសម្រេច ។

រដ្ឋាភិបាលបរទេស ដែលត្រូវការចង់បានទីដីនៅពុទ្ធគយាត្រូវទាក់ទងជាមួយនឹងរដ្ឋាភិបាលឥណ្ឌាឲ្យបានមុនចុងខែឧសភាមុខនេះ ។

រដ្ឋាភិបាលពិហារនឹងរៀបចំលក្ខន្តិកៈ ព្រមទាំងផែនទីដីដែលត្រូវបែងចែកគ្នានោះផ្សាយជូនសមាជិកទាំងអស់ជ្រាប នៅពេលប្រជុំលើកក្រោយ ។

នៅទីបំផុត, មានការថ្លែងអំណរគុណចំពោះលោកប្រធាននឹងសេចក្ដីថ្លែងរបស់គណៈប្រតិភូចិន ទើបសម័យប្រជុំបានបិទនៅវេលាម៉ោង ១៧ នឹង១៥នាទី ។ សម័យប្រជុំលើកទី ២ នឹងចាប់ផ្ដើមធ្វើនៅចុងខែមិថុនាឬដើមខែកក្កដាមុខនេះ ។

### យោបល់របស់គណៈប្រតិភូនៃប្រទេសកម្ពុជា
### អំពីការប្រជុំខាងលើនេះ

ពុទ្ធគយាស្ថិតនៅក្នុងអំណាច, ក្នុងកណ្ដាប់ដៃនៃអ្នកកាន់សាសនាហិណ្ឌូនៅឡើយ

ព្រោះក្នុងបណ្ដាសមាជិកនៃគណៈកម្មាធិការចាត់ចែងការ៩រូបមានតែ៤រូបទេ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ក្រៅពីនោះសុទ្ធតែអ្នកកាន់សាសនាហិណ្ឌូ ។ ក្នុងគណៈកម្មាធិការទីប្រឹក្សាទៀតសោត ក៏មានជនជាតិឥណ្ឌៀភាគច្រើនណាស់ ដោយហេតុនេះ គួរតែគ្រប់ប្រទេសពុទ្ធសាសនិកទាំងអស់ ចាត់អ្នកតំណាងឲ្យទៅកាន់ទីប្រជុំកុំបីខកខាន ។

ដើម្បីឲ្យមានឋានៈ ប្រសើរក្នុងគណៈកម្មាធិការ ចំពោះសេចក្ដីសម្រេចនីមួយៗ ដែលពុំគប្បីជាប្រយោជន៍ចំពោះប្រទេសឥណ្ឌៀតែមួយទេ គឺត្រូវតែជាគុណប្រយោជន៍ចំពោះប្រទេសពុទ្ធសាសនិកទាំងអស់ ។

ក្នុងកិច្ចប្រជុំប្រៀបរៀបចំសម្រាប់ពិធីបុណ្យស្រម្ពោធពុទ្ធសករាជ ២៥០០ នោះនៅសល់តែការបន្តិចបន្តួចជិតនឹងសម្រេចអស់ហើយ ។

ក្នុងមណ្ឌលពុទ្ធគយាមានផ្ទះសំណាក់ជាច្រើន ដែលកំពុងតែសាងសង់សម្រាប់ទទួលបូជនីយេសន៍ ។ ការរៀបចំនៅក្រុងពជគ្រឹះ ក៏ជិតតែនឹងសម្រេចហើយដែរ ៗ ទាំងការរៀបចំនៅនាបូជនីយស្ថានដទៃ ៗ ទៀតក៏គេបានប្រាប់ថា មុខជានឹងហើយស្រេចក្នុងពេលឆាប់ ៗ នេះដូចគ្នាដែរ ។

ប្រទេសកម្ពុជាគួរតែសុំឲ្យបានទីដីមួយកន្លែង នៅក្នុងមណ្ឌលពុទ្ធគយាដែលជាបូជនីយស្ថានដ៏ពិសិដ្ឋ ក្នុងព្រះពុទ្ធសាសនា ដើម្បីសាងសង់ព្រះវិហារ, កុដិនឹងសាលាសំណាក់ទុកជាកិត្តិយសប្រទេសជាតិយើងតទៅអនាគត ។

ក្នុងពេលដែលគណៈប្រតិភូខ្មែរនៅសំណាក់ក្នុងមន្ទីរមហាពោធិសមាគមក្រុងកាលកត្តា, លោកអគ្គលេខាធិការបានប្រាប់ថា ព្រះអរហន្តធាតុនៃព្រះមហាមោគ្គលីបុត្ត-

តិស្សត្ថេរ ព្រមទាំងព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ ដទៃខ្លះទៀត ដែលប្រទេសឥណ្ឌៀទើបបានពីប្រទេសអង់គ្លេសមកនោះ រដ្ឋាភិបាលឥណ្ឌៀ ព្រមជូនទៅរដ្ឋាភិបាលលង្កា តាមសេចក្ដីសុំរបស់រដ្ឋាភិបាល លង្កាហើយ បើប្រទេសកម្ពុជាត្រូវការបង់បានគួរធ្វើពាក្យសុំចំពោះរដ្ឋាភិបាលលង្កា ។ លុះគណៈប្រតិភូខ្មែរមកដល់ក្រុងរង្គូនប្រទេសភូមា ក៏បានឱកាសចូលទៅគោរពចំពោះព្រះអរហន្តធាតុ នៃព្រះមហាមោគ្គលីបុត្តតិស្សត្ថេរ ដែលរដ្ឋាភិបាលភូមា ទើបបានទិមន្តមកពីប្រទេសឥណ្ឌៀដើម្បីជាទីគោរពព្រះអរហន្តធាតុនោះមានតែបួនដុំប៉ុណ្ណោះ ។

ព្រះសង្ឃសត្ថាប-ស ធម្មាភោ ជាប្រតិភូ

សាមណេរ ស-ហ ធម្មរតន ជាអ្នកប្រែភាសា

---

## ពាក្យថ្មីរបស់គណកម្មការវប្បធម៌ ដែលប្រែចេញពីភាសាបារាំង

| | |
|---|---|
| Clique | តក្កពួក |
| Coefficient | មេគុណ ចំនួនបង្កើន |
| Collection | សមុហកម្ម |
| Comices agricoles | សន្និបាតកសិករ |
| Commando cynophile : | កងពិសេសសុនខកក្ដី |
| Commissariat général de l'exposition Internationale de Phnom penh: | ស្ថានអគ្គស្នងការនៃពិពណ៌អន្តរជាតិ ក្រុងភ្នំពេញ |

| | |
|---|---|
| Commission | គណៈកម្មការ កម្រៃជើងសារ |
| Compte | គណនី |
| Compétition | ការប្រជែង |
| Connaissement; | អញ្ញាតបណ្ណ សមុទ្រពាណិជ្ជ |
| Conseil d'administration: | ក្រុមប្រឹក្សាភិបាល |
| Consignation | ការផ្ញើទុកបញ្ញើ |
| Contrôle des changes | ការពិនិត្យប្តូរប្រាក់ |
| Contrôle général | ពិនិត្យឧកាស |
| Contrôleur général | អគ្គពិនិត្យ |
| Copie conforme transmise à: | ចម្លងត្រូវបញ្ជូនមក |
| Echange | ការប្តូរ |
| Echéance | ឥណៈសោធារ, ពេលសងបំណុល |
| Echanges compensés | ការប្តូរទូទាត់ |
| Effet à payer | ផលប័ត្រ សម្រាប់ទទួល |
| Effet de commerce: | ពាណិជ្ជប័ត្រ |
| Egaler | ត្រូវការ „ទព្វន្ត,, ស្មើជា ... |
| Egotisme | អហង្ការនិយម |
| Egotiste | អ្នកអហង្ការ |
| Emulation: | សារម្ភ ការដណ្តើមដើមគ្នា ការប្រណាំងប្រជែង |

| | |
|---|---|
| Endossement d'un chéque | ការចារខ្នងមូលប្បទានប័ត្រ |
| Escompte | ការប្រាក់បំណុល |
| Escompte | អបហារ ការដកយកតម្លៃជាមុន |
| Ethnographie: | ជាតិពន្ធពណ៌នា |
| Ethnologie: | ជាតិពន្ធវិទ្យា |
| Ex- acquo | សមានរូប |
| Ex emple . | ឧទាហរណ៍ |
| Exercice écrit | ការហាត់ដោយសរសេរ |
| Exercice oral | ការហាត់ដោយវាចា |
| Expertise | កោសលវិនិច្ឆ័យ ការពិនិត្យរបស់ជំនាញ |
| Exposant | អ្នកពិពណ៌ |
| Expression fractionnaire | សំនួនប្រភាគ |
| Extrême | អច្ចន្តភាគ បទកោដិ-កោដិភាគ |
| Faculté | សក្តានុភាព |
| Festivale | មហោស្រព |
| Filio | ខង្កាប្រចាំថ្ងៃ |
| Fonds de commerce | មូលនិធិពាណិជ្ជកម្ម |
| Fraction | ប្រភាគ |
| Frais échus | អគ្ឃប្រាប្ត សោហ៊ុយ ឬតម្លៃដែលកំណត់ត្រូវ<br>សង |

| | |
|---|---|
| Fret | នាវាវេតន៍ថ្លៃឈ្នួលកុប៉ាល |
| Gradin | វេទិកាបទ ថ្នាក់វេកា |
| Général | អគ្គ-អគ្រ-ឧត្តម-ឧភាស-ទូទៅ-សាកល |
| Gouverneur de la banque nationale | ទេសាភិបាលធនាគារជាតិ |
| Grâce | សុន្ទរភាព - មោទនីយភាព - ករុណាភាព |
| | អនុគ្រោះ |
| Grand livre | សៀវភៅធំ |
| Grotte | រូងភ្នំ |
| Groupe | សមុទាយ - ពួក បន |
| Groupement | សមុទាយភាព - វគ្គភាព ការរួមគ្នាជាពួក |
| Image | រូបនិមិត្ត |
| Immobilisation | អសញ្ហារិមកម្ម |
| Imputable | គួររាប់បញ្ចូលគួរទម្លាក់ទោស |
| Inculquer | ផ្ញុបចិត្ត |
| Infirmerie vétérinaire | គិលានុបដ្ឋានបសុពេទ្យ |
| Infirmier chef | គិលានុបដ្ឋាកនាយ |
| Infirmier vétérinaire | គិលានុបដ្ឋាកបសុពេទ្យ |
| Des F.A.R.K. | ស. ខ. ក. |
| Information | និវេទន៍ ការឲ្យដំណឹង |
| Innocence | និរទោស-នេលភាព |
| Innocent | និរទោស-ជានេលភាព |

(នៅមានត)

រោងពុម្ពទរីយ

នៅខាងត្បូងផ្សារអូរឬស្សីសង្កាត់លេខ៥